

# របាយការណ៍ស្រាវជ្រាវ

## ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន និងសេវាសាធារណៈ

**គាំទ្រថវិកាដោយ**

ស្ថានទូតជប៉ុន និងUNDP តាមរយៈអង្គការសម្ព័ន្ធដៃគូរ
ដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (CPDD)

**អនុវត្តដោយ**

អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម

**បោះពុម្ព**

កាលបរិច្ឆេទ៖ ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២៣

# មាតិកា


សេចក្តីថ្លែងអំណរគុណ............................................................................................२

បញ្ជីរូបភាព ............................................................................................................ ៣

១.សេចក្តីសង្ខេបការស្រាវជ្រាវ....................................................................................៤

២.សេចក្តីផ្តើម ........................................................................................................៧

៣.វិធីសាស្ត្រស្រាវជ្រាវ .............................................................................................. ៩

៣.១ គោលបំណងស្រាវជ្រាវ ...................................................................................... ៩

៣.២ សំណួរស្រាវជ្រាវ .............................................................................................. ៩

៣.៣ ប្រភពទិន្នន័យ .................................................................................................. ៩

៣.៤ វិធីសាស្ត្រ និងបច្ចេកទេសស្រាវជ្រាវ ................................................................ ១០

៣.៥ ទំហំគំរូសំណាក ................................................................................................ ១០

៣.៦ ដំណើរការស្រាវជ្រាវ........................................................................................ ១១

៣.៧ ការធានាគុណភាពទិន្នន័យ និងការវិភាគទិន្នន័យ ..................................................១២

៣.៨ ការឆ្លើយតបយេនឌ័រ និងបរិសាយប័ន្ននៅក្នុងដំណើរការប្រមូលទិន្នន័យ ......................១២

៣.៩ របសម្ព័ន្ធនៃវិធីសាស្ត្រស្រាវជ្រាវ...........................................................................១៣

៤.ប្រជាសាស្ត្រ និងភូមិសាស្ត្រ.....................................................................................១៣

៥.លទ្ធផលស្រាវជ្រាវ............................................................................................... ១៤

៥.១ ព័តមានទូទៅរបស់អ្នកចូលរួម ............................................................................. ១៤

៥.២ ការយល់ដឹងរបស់យុវជន និងប្រជាសហគមន៍អំពីអភិបាលកិច្ចមូលដ្ឋាន ...................... ១៥

៥.៣ ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់និងក្រុង................២៣

៥.៤ ការយល់ដឹងរបស់យុវជន និងប្រជាសហគមន៍អំពីការចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋាន................ ៣៧

៥.៥ ការយល់ដឹងរបស់អាជ្ញាធរ និងអ្នកពាក់ព័ន្ធអំពីអភិបាលកិច្ចមូលដ្ឋាន .........................៣៨

៦.សេចក្តីសន្និដ្ឋាន................................................................................................. ៤៦

៧.ឯកសារយោង ...................................................................................................... ៥០

# សេចក្តីថ្លែងអំណរគុណ

អង្គការសម្ព័ន្ធដើម្បីសុចរឹតភាព និងគណនេយ្យភាពសង្គម (CISA) សូមថ្លែងអំណរគុណស្ថានទូតជប៉ុន អង្គារ UNDP និងអង្គការសម្ព័ន្ធដៃគូរដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (CPDD)ដែលបានគាំទ្រជាថវិកា សម្រាប់ការអនុវត្តគម្រោង "លើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ" និងសម្រាប់ដំណើរការស្រាវជ្រាវស្តីពី "**ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន និងសេវាសាធារណៈនៅក្នុងក្រុងកំពង់ចាម**"។

អង្គការCISA ក៏សូមអរគុណចំពោះអាជ្ញាធរសង្កាត់ អាជ្ញាធរក្រុងកំពង់ចាម និងការិយាល័យពាក់ព័ន្ធទាំងអស់ដែលបានចូលរួមគាំទ្រ សហការណ៍ និងការអនុវត្តការស្រាវជ្រាវនេះ ដោយបានផ្តល់ជាព័ត៌មាន ជាទិន្នន័យ ជាឯកសារ និងជាការសម្ភាសន៍ផ្ទាល់មាត់ផងដែរ។

លើសពីនេះ អង្គការ CISA ក៏សូមអរគុណដល់បុគ្គលិកគម្រោង និងបណ្តាញយុវជនសហគមន៍ ជាពិសេសអរគុណ លោក **ជោត ហេង** ប្រធានកម្មវិធីអង្គការCISA ដែលបានដឹកនាំ និងសម្របសម្រួលដល់មន្ត្រីគម្រោង និងបណ្តាញយុវជនសហគមន៍សម្រាប់ដំណើរការស្រាវជ្រាវតាំងពីការចាប់ផ្តើមរហូតដល់ការរៀបចំជាសិក្ខាសាលាបង្ហាញលទ្ធផលស្រាវជ្រាវដល់អាជ្ញាធរសង្កាត់ ក្រុង និងអ្នកពាក់ព័ន្ធជាច្រើនក្នុងគោលបំណង់ស្វែងរកព័ត៌មានត្រឡប់ និងទិន្នន័យបញ្ចូលបន្ថែម និងរហូតដល់ការបញ្ចប់ការសរសេររបាយការណ៍ស្រាវជ្រាវនេះ។

អង្គការ CISA ក៏អរគុណចំពោះសហការីទាំងអស់ដែលបានចូលរួមពាក់ព័ន្ធ និងសហការហ៍ជាមួយក្រុមអ្នកស្រាវជ្រាវរបស់យើង ជាពិសេសក្នុងការបង្កើតកម្រងសំណួរ ការចុះជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋសហគមន៍ បុគ្គលសំខាន់ៗ ការរៀបចំពិភាក្សាក្រុម និងការខិតខំប្រឹងប្រែងលើដំណើរការអនុវត្តគម្រោងផងដែរ ។

ក្នុងនាមខ្ញុំជាអ្នកដឹកនាំមួយរូបតំណាងឲ្យគណៈគ្រប់គងអង្គារCISAទាំងអស់ សូមគោរពជូនពរឱ្យអ្នកចូលរួម និងអ្នកពាក់ព័ន្ធទាំងអស់គ្នាជួបតែសេចក្តីសុខ ចំរើន និងសំណាងល្អគ្រប់ពេលវេលា។

ភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ២០២៣

## បញ្ជីរូបភាព

រូបភាពទី១៖ រចនាសម្ព័ន្ធនៃដំណើរការស្រាវជ្រាវ
រូបភាពទី២៖ ភេទរបស់អ្នកចូលរួមឆ្លើយសំណួរសម្ភាសន៍
រូបភាពទី៣៖ ក្រុមជាតិសាសន៍របស់អ្នកចូលរួមឆ្លើយសំណួរសម្ភាសន៍
រូបភាពទី៤៖ អាយុរបស់អ្នកចូលរួមឆ្លើយសំណួរសម្ភាសន៍
រូបភាពទី៥៖ ការងាររបស់អ្នកចូលរួមឆ្លើយសំណួរសម្ភាសន៍
រូបភាពទី៦៖ ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីអភិបាលកិច្ចមូលដ្ឋាន
រូបភាពទី៧៖ ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីការអនុវត្តផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាសង្កាត់និងក្រុង
រូបភាពទី៨៖ ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់និងក្រុង
រូបភាពទី៩៖ ការដឹង និងស្គាល់របស់ប្រជាពលរដ្ឋអំពីការិយាល័យសេវាសាធារណៈ
រូបភាពទី១០៖ ការចូលរួមប្រជាពលរដ្ឋក្នុងការផ្តល់សេវាកម្មសាធារណៈរបស់សង្កាត់ និងក្រុង
តារាងលទ្ធផលទី១៖ ការយល់ដឹងរបស់យុវជន និងប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
តារាងលទ្ធផលទី២៖ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីអភិបាលកិច្ចមូលដ្ឋាន

## ១.សេចក្តីសង្ខេបការស្រាវជ្រាវ

នៅក្នុងខែមិថុនា ឆ្នាំ២០២៣ អង្គការសម្ព័ន្ធដើម្បីសុចរឹតភាព និងគណនេយ្យភាពសង្គម (CISA) បានទទួលការអនុមត្តិថវិកាពីអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រោមថវិកាជំនួយពីស្ថានទូតជប៉ុន និងអង្គការ UNDP សម្រាប់ការអនុវត្តគម្រោង "**លើកកម្ពស់តម្លាភាព និងគនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**"។ គម្រោងនេះមានគោលបំណងដើម្បីផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងបុរសនៅក្នុងក្រុមដែលខ្វះខាត និងងាយរងគ្រោះដើម្បីបានចូលរួមក្នុងការរៀបចំផែនការ ថវិកា និងសេវាសាធារណៈប្រកចេញចូលតែមួយ និងដើម្បីស្វែងរកការឆ្លើយតប និងការចាត់វិធានការយ៉ាងរហ័សដោយអាជ្ញាធរមូលដ្ឋាននៅថ្នាក់ក្រុងកំពង់ចាម លើតម្រូវការរបស់ស្ត្រី និងបុរសដែលស្ថិតក្នុងក្រុមដែលខ្វះខាត និងងាយរងគ្រោះ។

ផ្នត់គំនិតនៃអភិបាលកិច្ចល្អត្រូវបានពិចារណា និងអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ២០០២ តាមរយៈការធ្វើវិមជ្ឈការ និងវិសហមជ្ឈការអំណាច ធនធាន មុខងារ និងតួនាទីមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីមានគោលនយោបាយ និងការបញ្ជ្រាបការយល់ដឹងស្តីពីអភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការដល់ប្រជាសហគមន៍ អាជ្ញាធរ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានតាំងពីឆ្នាំ២០០៣ ដំណើរការអភិបាលកិច្ចល្អ និងសេវាសាធារណៈនៅមូលដ្ឋាន (ជាពិសេសសេវាប្រកចេញចូលតែមួយ) ហាក់បីមិនទាន់មានប្រសិទ្ធិភាពនៅឡើយ ពីព្រោះថាគម្លាតនៃការចូលរួមរបស់យុវសហគ្រិន ប្រជាសហគមន៍ និងជាពិសេសក្រុមជនងាយរងគ្រោះត្រូវបានរាយការណ៍ថានៅមានកំរិតទាបនៅឡើយ។ បើយោងតាមរបាយការណ៍ស្រាវជ្រាវមួយស្តីពី "**ឧបសគ្គនៃការប្រើប្រាស់សេវាកម្មការិយាល័យប្រកចេញចូលតែមួយ និងការយល់ដឹងស្តីពីសិទ្ធសេដ្ឋកិច្ចសង្គមរបស់សហគ្រិនវ័យក្មេង**" របស់អង្គការសម្ព័ន្ធដើម្បីសុចរឹតភាព និងគណនេយ្យភាពសង្គមក្នុងខែវិច្ឆិការ ឆ្នាំ២០២១ នៅទំព័រ២១ បានបង្ហាញឲ្យឃើញថា មានយុវសហគ្រិន និងប្រជាសហគមន៍ចំនួន៦៧% បានស្នើសុំដល់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធបង្កើនការផ្សព្វផ្សាយអប់រំ និងបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋ ជាពិសេសដល់សហគ្រិនវ័យក្មេងទាំងនៅក្នុងក្រុង និងនៅក្រៅក្រុងឲ្យបានដឹង និងយល់ច្បាស់ពីសិទ្ធសេដ្ឋកិច្ចសង្គម និងសេវាកម្មសាធារណៈ ជាពិសេសសេវាកម្មការិយាល័យប្រកចេញចូលតែមួយ ។

ការស្រាវជ្រាវនេះមានគោលបំណងដើម្បីវាយតម្លៃការយល់ដឹងរបស់ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីប្រសិទ្ធភាព និងគម្លាតនៃអភិបាលកិច្ចល្អ និងការផ្តល់សេវាសាធារណៈ ជាពិសេសសេវាកម្មការិយាល័យប្រកចេញចូលតែមួយរបស់សាលាក្រុងកំពង់ចាម និងមានបំណងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមងាយរងគ្រោះ ក្នុងអភិបាលកិច្ចមូលដ្ឋាន ការផ្តល់សេវាសាធារណៈ និងវេទិកាតស៊ូមតិគោលនយោបាយ។

វិធីសាស្ត្រសម្រាប់ការស្រាវជ្រាវនេះ ត្រូវបានកំណត់ចំនួនសំណាកតាមគោលបំណង និងចៃដន្យ ។ វាមានន័យថា អ្នកប្រមូលទិន្នន័យ ត្រូវបានតំរង់ទិសឲ្យជួបសម្ភាសន៍ជាមួយបុគ្គលសាមញ្ញៗចំនួន២០០នាក់ (ស្ត្រី៦០%) ជួបសម្ភាសន៍ជាមួយបុគ្គលសំខាន់ៗដែលជាមន្ត្រីអាជ្ញាធរមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាលចំនួន៤០នាក់ និងពិភាក្សាក្រុម៤ក្រុមដែលមានអ្នកចូលរួមចំនួនប្រមាណ៣៥នាក់) ដែលអញ្ជើញមកពីសង្កាត់ទាំង៤ក្នុងក្រុងកំពង់ចាមក្រោមចំណោទសំណួរជាចម្បងមួយថា **"តើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅសាលាក្រុងកំពង់ចាមមានសភាពយ៉ាងដូចម្តេច?"**

ជាលទ្ធផល ការស្រាវជ្រាវនេះបង្ហាញឲ្យឃើញថា ការយល់ដឹងរបស់យុវជន និងប្រជាសហគមន៍អំពីអភិបាលកិច្ចមូលដ្ឋាន និងសេវាកម្មសាធារណៈ គិតជាមធ្យមភាគ អ្នកមិនយល់ដឹងសោះ មាន៧២% អ្នកយល់ដឹងតិចតួច មាន១៧.៧% អ្នកយល់ដឹងជាបង្គួរ មាន៧.៤% អ្នកយល់ដឹងល្អ មាន២.៥% និង យល់ដឹងច្បាស់ មានចំនួន ០.៤% ។

ដោយឡែក ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធអំពីអភិបាលកិច្ចមូលដ្ឋាន និងសេវាកម្មសាធារណៈ វាបានបង្ហាញថា អ្នកដែលមិនយល់ដឹងសោះ មាន២២.៨% អ្នកយល់ដឹងតិចតួច មាន២៥% អ្នកយល់ដឹងបង្គួរ មាន៣៨.៨% អ្នកយល់ដឹងបានល្អ មាន១២.១% និងអ្នកដែលយល់ដឹងច្បាស់ មានចំនួន១.២%។

ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់និងក្រុង ជាលទ្ធផលមធ្យមភាគ វាបង្ហាញឲ្យឃើញថាម មានអ្នកមិនយល់សោះ មាន៧៥% អ្នកយល់តិចតួច មាន១៥.៩% អ្នកយល់ដឹងបង្គួរ មាន៦.៧% អ្នកយល់ដឹងបានល្អ មាន១.៩% និងអ្នកយល់ដឹងល្អណាស់ មាន០.៥%។

ការដឹង និងស្គាល់របស់យុវជន និងប្រជាសហគមន៍អំពីការិយាល័យ និងសេវាសាធារណៈ នៅកំរិតសង្កាត់ និងក្រុងកំពង់ចាម គិតជាមធ្យមភាគ អ្នកមិលស្គាល់ ឬមិនដឹង មានចំនួន៦១.៩% និងអ្នកដឹង ឬស្គាល់មានចំនួន ៣៨.៩១% ។

នៅក្នុងរូបភាពទី៥ វាបង្ហាញថា មានយុវជន និងប្រជាពលរដ្ឋប្រមាណ៩១.៩២% មិនធ្លាប់ ឬមិនបានចូលរួម ឬពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មរបស់ក្រុមប្រឹក្សាសង្កាត់ និងក្រុង គឺមានតែ៨.៨% បានចូលរួម និងពាក់ព័ន្ធក្នុងដំណើរការផ្តល់សេវាកម្មរបស់ក្រុមប្រឹក្សាសង្កាត់និងក្រុងកំពង់ចាម។

ដើម្បីឆ្លើយតបទៅនឹងការរកឃើញខាងលើ ទាំងយុវជន ប្រជាសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ បានលើកជាសំណូមពរ និងអនុសាសន៍ ថាក្រុមប្រឹក្សាសង្កាត់ និងក្រុងគួរសម្របសម្រួលឱកាសឲ្យយុវជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធបានចូលរួមប្រជុំជាមួយសង្កាត់ និងក្រុងជាប្រចាំ និងទៀងទាត់ និងមានឱកាសចូលរួមក្នុងការងាររបស់គណៈកម្មាធិការនានារបស់សង្កាត់ និងក្រុង ដូចជាគណៈកម្មាធិការកសាងផែនការ និងថវិការបស់សង្កាត់ និងក្រុង។ លើសពីនេះក្រុមប្រឹក្សាសង្កាត់ និងក្រុងគួររៀបចំ និងផ្សព្វផ្សាយកាលវិភាគការប្រជុំប្រចាំ

ដល់យុវជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ដែលផ្តល់ឱកាសឲ្យពួកគេ ជាពិសេសអ្នកធ្វើការនៅរោងចក្រ យុវជនជាសិស្សអាចចូលរួមបានផងដែរ។

ក្រុងប្រឹក្សាសង្កាត់ និងក្រុង និងអ្នកបំរើសេវាសាធារណៈគួរចូលធ្វើការម៉ោង៧:០០ព្រឹក តាមម៉ោងពេល ការផ្តល់សេវាឲ្យបានលឿន សមរម្យ ថ្លៃថ្នូរ និងត្រឹមត្រូវ ជៀសវាងមានកំហុសលើឯកសារ ដូចជាអត្តសញ្ញាណប័ន សំបុត្រកំណើត និងសៀវភៅគ្រួសារជាដើម។ លើសពីនេះ មន្ត្រីបំរើការងារនៅសង្កាត់ និងក្រុងស្នើឲ្យមានភាពសមរម្យ កុំតឹងតែង នៅពេលប្រជាពលរដ្ឋទៅរកសេវា។ បន្ថែមជាមួយការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋអំពីនីតិវិធីនៃការផ្តល់សេវា តម្រូវការឯកសារពាក់ព័ន្ធត្រូវយកទៅជាមួយ នៅពេលធ្វើឯកសារអ្វីមួយ។

ក្រុមប្រឹក្សាសង្កាត់ និងក្រុងគួរចុះផ្ទាល់មកមើលប្រជាពលរដ្ឋតាមភូមិ ថាតើពួកគាត់ពិតជាក្រីក្រ ពិតជាត្រូវការជំនួយមែនទេ មុនពេលផ្តល់ប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋ។ ភូមិឃុំ និងក្រុងគួរដើរមើលប្រជាពលរដ្ឋដើម្បីដោះស្រាយទំនាស់ និងតម្រូវការភាពខ្វះខាតរបស់យុវជន និងប្រជាពលរដ្ឋដោយមានតម្លាភាព គណនេយ្យភាព សុចរិតភាព និងស្មើភាព។

ប៉ូលីស ក្រុមប្រឹក្សាសង្កាត់ និងក្រុងសូមជួយមើលបញ្ហាក្មេងទំនើង ការបង្អោះម៉ូតូ គ្រឿងញៀន អំពើហឹង្សា និងអសន្តិសុខនានាដែលកើតមាននៅភូមិឃុំ ដើម្បីរក្សាបាននូវភូមិឃុំសុវត្ថិភាព អនាម័យបរិស្ថាន និងការអភិវឌ្ឍជឿនលឿន ។ ក្រុមប្រឹក្សាសង្កាត់ និងក្រុងគួរពិចារណាធ្វើផ្លូវថ្នល់ ភ្លើង លូ ឲ្យបានលឿនៗ និងអភិវឌ្ឍន៍ក្រុងប្រកបដោយបៃតង។

## ២.សេចក្តីផ្តើម

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ស្រុក ក្រុង ខ័ណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់ បានតម្រូវឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ខ្លួនជាចាំបាច់ ព្រោះថាផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា និងតម្រូវការអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។ រាល់ការកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ តាមប្រព័ន្ធលើកកម្ពស់សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម ដែលក្នុងនោះអាចមកពីសង្គមស៊ីវិល ក្រុមយុវជន ក្រុមស្ត្រី ក្រុមជនជាតិដើមភាគតិច ជនមានពិការភាព និងក្រុមជនងាយរងគ្រោះផ្សេងៗ និងមកពីក្រុមវិស័យឯកជនផងដែរ។

កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក៏គឺជាដំណើការនៃការកសាងផែនការអភិវឌ្ឍអាទិភាព និងការធ្វើការសម្រេច ចិត្តនៅថ្នាក់ក្រោមជាតិ និងវាជាផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដោយរាជរដ្ឋាភិបាលកម្ពុជា។ វាជាការសំខាន់ណាស់ ដែលតម្រូវការរបស់ជនពិការ ក្រុមជនជាតិដើមភាគតិច ក្រុមយុវជន ក្រុមស្ត្រី និងក្រុមជនងាយរងគ្រោះផ្សេងៗ នៅសហគមន៍ត្រូវបានទទួលស្គាល់នៅគ្រប់ផ្នែកនៃការអភិវឌ្ឍថវិការ។ ដើម្បីសម្រេចបានគោលដៅនៃការអភិវឌ្ឍសហគមន៍ និងសង្គមជាតិប្រកបដោយចិរភាព សង្គមស៊ីវិល ក្រុមយុវជន ក្រុមស្ត្រី ក្រុមជនជាតិដើមភាគតិច ជនមានពិការភាព និងក្រុមជនងាយរងគ្រោះផ្សេងៗចាំបាច់ត្រូវចូលរួមគ្រប់ដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគឃុំសង្កាត់ និងស្រុកក្រុង ដោយសារពួកគាត់ដឹងច្បាស់អំពីអ្វីដែលពួកគាត់ត្រូវការ និងអ្វីដែលអាចជួយពួកគាត់ក្នុងការអនុវត្តសិទ្ធិ និងកត្តព្វកិច្ចពីការចូលរួមរបស់គាត់ឱ្យបានពេញលេញ។

បើផ្អែកតាម ការណែនាំបច្ចេកទេសពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គោលការណ៍នៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍មូលដ្ឋានត្រូវឈរលើគោលការណ៍សំខាន់ៗ ដូចជា ការចែករំលែកព័ត៌មាន សង្គតិភាព និងសុខដុមនីយកម្ម ការចូលរួមពិគ្រោះយោបល់ទូទៅ ការឆ្លើយតមនឹងតម្រូវការ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន និងការធានាសមធម៌យេនឌ័រ និងបរិយាប័ន្ន។

**អភិបាលកិច្ចមូលដ្ឋាន** ត្រូវបានទទួលស្គាល់ថាជាបញ្ហាប្រឈមដ៏សំខាន់បំផុតសម្រាប់ដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតាមបែបប្រជាធិបតេយ្យនៅកម្ពុជា។ អភិបាលកិច្ចល្អ ទាមទារមិនត្រឹមតែការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែទាមទារការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជន។ រ

ដ្ឋាភិបាលកម្ពុជា បាននិងកំពុងផ្តួចផ្តើមគំនិតផ្សេងៗដើម្បីកែលម្អអភិបាលកិច្ចពី "ខាងក្នុង" ។ ការសិក្សានេះផ្តោតលើតួនាទី សិទ្ធិ និងទំនួលខុសត្រូវ របស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល (CSOs) ក្នុងការធានានូវតម្រូវការប្រកបដោយប្រសិទ្ធភាពសម្រាប់អភិបាលកិច្ចល្អ។

យោងតាមរបាយការណ៍វាយតម្លៃរបស់ធនាគារពិភពលោក ឆ្នាំ២០០៩ ស្តីពីការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អនៅកម្ពុជាបាននិយាយថា **គណនេយ្យភាពសង្គម** សំដៅលើសកម្មភាព និងយន្តការដ៏ទូលំទូលាយដែលបង្កើតដោយរដ្ឋាភិបាល។ និងដែលប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីជួយរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាព ក៏ដូចជាសកម្មភាពរបស់រដ្ឋាភិបាល សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតួអង្គសង្គមដទៃទៀតដែលផ្សព្វផ្សាយ ឬជួយសម្រួលដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ។ ការអនុវត្តគណនេយ្យភាពសង្គម រួមមានការខិតខំប្រឹងប្រែងរបស់ពលរដ្ឋ អង្គការសង្គមស៊ីវិល និង រដ្ឋបាលថ្នាក់ជាតិ និងក្រោមជាតិដើម្បីទទួលបានព័ត៌មានកាន់តែប្រសើរអំពីកម្មវិធីអភិវឌ្ឍន៍ សកម្មភាព និងថវិការបស់រដ្ឋាភិបាល ប្រាស្រ័យទាក់ទងជាសាធារណៈនូវមតិ និងតម្រូវការរបស់ពួកគេតាមរយៈការស្ទង់មតិសាធារណៈ វេទិកាសាធារណៈ និងការផ្តល់ព័ត៌មានត្រឡប់ ការវិភាគ និងការផ្តល់មតិកែលម្អលើឯកសារសាធារណៈសំខាន់ៗ (ឧ. គោលនយោបាយឯករាជ្យ ឬការវិភាគថវិកា) ការតាមដានការចំណាយសាធារណៈ (ឧ. ថវិកាសាលា ឬមូលនិធិក្រុមប្រឹក្សាឃុំសង្កាត់) ការតាមដាន និងការវាយតម្លៃសេវារបស់រដ្ឋាភិបាល (ឧ. ការប្រើសវនកម្មសង្គម កាតរបាយការណ៍ពលរដ្ឋ ឬប័ណ្ណពិន្ទុសហគមន៍) ការត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល (ឧ. សារព័ត៌មានស៊ើបអង្កេត ឬការស្ទង់មតិអំពើពុករលួយ) និង ការរួមចំណែកដល់ដំណើរការនៃការសម្រេចចិត្តជាសាធារណៈ (ឧ. ការចូលរួមរបស់ប្រជាពលរដ្ឋ/CSO នៅក្នុងក្រុមប្រឹក្សាសាធារណៈ ឬក្រុមការងារ)។

ការចូលរួមរបស់ពលរដ្ឋ និងគណនេយ្យភាពសង្គមនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្រួច និងដាក់ឥទ្ធិពលដោយកត្តាបរិបទមូលដ្ឋានមួយចំនួន។ កត្តាជម្លោះខាងផ្នែកនយោបាយ នាពេលថ្មីៗនេះ បានធ្វើឱ្យចុះខ្សោយនូវទំនុកចិត្ត និងការចុះសម្រុងគ្នាក្នុងសង្គម ហើយបណ្តាលឱ្យមានកម្រិតទាបនៃសកម្មភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ សមាគម សហគមន៍ ជាពិសេសនៅតំបន់ជនបទ។ វាក៏បាននាំឲ្យមានការភ័យខ្លាចពីអាជ្ញាធរ និងការចង់បានសន្តិភាព និងសុខដុមរមនាក្នុងសង្គមយ៉ាងខ្លាំងផងដែរ។

អង្គការក្រៅរដ្ឋាភិបាលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតាមបែបប្រជាធិបតេយ្យនៅកម្ពុជា ជាពិសេសតាមរយៈសកម្មភាពលើកកម្ពស់ការយល់ដឹង និងបណ្តុះបណ្តាល ប៉ុន្តែការយល់ឃើញរបស់អង្គការសង្គមស៊ីវិលដែលរួមចំណែកដល់អភិបាលកិច្ចល្អ តាមរយៈការស្វែងរក និងផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋាភិបាល ចូលរួមក្នុងដំណើរការការពិចារណា និងការសម្រេចចិត្តជាសាធារណៈ ហើយការទំនួលខុសត្រូវរបស់រដ្ឋាភិបាលគឺពិបាក។

បញ្ហាប្រឈមនេះ ជាហេតុជំរុញចិត្តដល់អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA) រៀបចំគម្រោង "ពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ" ក្នុងគោលបំណងដើម្បីពង្រឹងអភិបាលកិច្ចល្អ តម្លាភាព គណនេយ្យភាព និងការធ្វើផែនការថវិការបស់រដ្ឋបាលក្រុងកំពង់ចាម តាមរយៈការបង្កើតវេទិកាពិគ្រោះយោបល់សម្រាប់ស្ត្រី បុរស ជនពិការ និងជនងាយរងគ្រោះផ្សេងៗចូលរួមក្នុងដំណើរការរៀបចំផែនការថវិកា និងការត្រួតពិនិត្យតាមដានលើការអនុវត្តផែនការនិងថវិការបស់សាលាក្រុងកំពង់ចាម ក្នុងឆ្នាំទី១ នៃអណត្តិ៥ឆ្នាំរបស់ក្រុមប្រឹក្សាក្រុង។

ការស្រាវជ្រាវនេះ គឺជាការស្ទង់មតិមួយខណៈពេលដែលអង្គការ CISA កំពុងអនុវត្តគម្រោង "ពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ" ក្នុងគោលបំណងដើម្បីវាយតម្លៃការយល់ដឹងរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ស្តីពីប្រសិទ្ធភាព និងគម្លាតនៃអភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈរបស់ឃុំសង្កាត់ និងសាលាក្រុងកំពង់ចាម សម្រាប់ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន ការផ្តល់សេវាសាធារណៈ និងវេទិកាតស៊ូមតិគោលនយោបាយ។

## ៣.វិធីសាស្ត្រស្រាវជ្រាវ

**៣.១ គោលបំណងស្រាវជ្រាវ៖** គឺដើម្បីសិក្សាឈ្វេងយល់ពីប្រសិទ្ធភាព និងគម្លាតនៃអភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈរបស់សាលាក្រុងកំពង់ចាម ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាសង្កាត់ និងក្រុងកំពង់ចាម។ ការរកឃើញនៃការស្រាវជ្រាវ គឺជាទិន្នន័យសម្រាប់ធ្វើការតស៊ូមតិជាមួយអ្នកពាក់ព័ន្ធដើម្បីពិនិត្យមើលលើគោលនយោបាយដើម្បីពង្រឹងតម្លាភាព និងគណនេយ្យភាពនៃសេវាសាធារណៈ។

**៣.២ សំណួរស្រាវជ្រាវ៖** សំណួរស្រាវជ្រាវដែលត្រូវបានយកមកពិភាក្សា និងចោទជាបញ្ហាចម្បងមួយគឺ **"តើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅសាលាក្រុងកំពង់ចាមមានសភាពយ៉ាងដូចម្តេច?"**

**៣.៣ ប្រភពទិន្នន័យ៖** សម្រាប់ការអនុវត្តការស្រាវជ្រាវ អ្នកដែលចូលរួមផ្តល់ជាព័ត៌មាន ឬទិន្នន័យបឋមដល់អ្នកស្រាវជ្រាវវ័យក្មេងគឺមានសមាជិកបណ្តាញយុវជនសហគមន៍ ប្រជាសហគមន៍ ជនពិការ និង LGBTQI+ ជនជាតិដើមភាគតិច សហគ្រិនស្ត្រីវ័យក្មេង អាជ្ញាធរមូលដ្ឋានដែលមានដូចជាក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីសាលាក្រុងកំពង់ចាម ។ល។ ដោយឡែក ទិន្នន័យបន្ទាប់បន្សំត្រូវបានដកស្រង់ចេញពីឯកសារដែលស្រាប់ ឯកសារពាក់ព័ន្ធ និងប្រព័ន្ធអ៊ិនធឺណេត។

**៣.៤ វិធីសាស្ត្រ និងបច្ចេកទេសស្រាវជ្រាវ៖** ដើម្បីឆ្លើយតមទៅនឹងសំណួរស្រាវជ្រាវ អ្នកស្រាវជ្រាវយុវវ័យក្មេងបានប្រើវិធីសាស្ត្រទាំងគុណភាព និងបរិមាណតាមរយៈការអនុវត្តសកម្មភាពចម្បងពីរ៖ ១). សិក្សាលើទិន្នន័យដែលស្រាប់ (ធ្វើ Desk Review) តាមប្រព័ន្ធអ៊ីនធើណេត និង លើឯកសារដែលទទួលបានពីការិយាល័យពាក់ព័ន្ធ និង ២). ចុះប្រមូលទិន្នន័យនៅមូលដ្ឋាននៃតំបន់គោលដៅក្នុងក្រុងកំពង់ចាម (ធ្វើ Raw Data) ។ សម្រាប់សកម្មភាពទីពីរនេះ អ្នកស្រាវជ្រាវយុវវ័យក្មេងបានអនុវត្តវិធីសាស្ត្រ និងបច្ចេកទេសដូចជា៖

១. ការណែនាំអំពីគោលបំណងនៃការស្រាវជ្រាវដល់អ្នកចូលរួមសម្ភាសន៍ អំពីសិទ្ធិចូលរួម ការដកខ្លួនចេញ និងការរក្សាការសម្ងាត់ ។ល។ និងការស្នើសុំចុះហត្ថលេខាលើទម្រង់យល់ព្រមពីអ្នកសម្ភាសន៍ និង

២.ការប្រើឧបករណ៍នៃការសម្ភាសន៍បុគ្គលសមញ្ញៗ (In-Depth Interview) ការសម្ភាសន៍បុគ្គលសំខាន់ៗ (Key Informant Interview) ការពិភាក្សាជាក្រុម (Focus Group Discussion) សម្រាប់ដំណើរការប្រមូលទិននន័យរបស់ខ្លួន ។

- **ការសម្ភាសបុគ្គលសាមញ្ញៗ៖** យុវជន ប្រជាសហគមន៍ សហគ្រិនស្ត្រី បុគ្គលស្រឡាញ់ភេទដូចគ្នា ក្រុមជនជាតិភាគតិច និងបុគ្គលសាមញ្ញប្រមាណ២០០នាក់ត្រូវបានលើកទឹកចិត្តឲ្យចូលរួម និងជួបសម្ភាសន៍ស៊ីជំរៅទៅតាមកម្រងបញ្ជីសំណួរដែលរៀបចំដោយអ្នកស្រាវជ្រាវយុវវ័យក្មេង (បណ្ដាញយុវជនសហគមន៍) របស់អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA) ។
- **ការសម្ភាសបុគ្គលសំខាន់ៗ៖** ដូចគ្នាទៅនឹង កម្រងសំណួរសម្ភាសន៍បុគ្គលសាមញ្ញផងដែរ អាជ្ញាធរមូលដ្ឋាន មន្ត្រីការិយាល័យអាក់ព័ន្ធ សង្គមនស៊ីវិល និងវិស័យឯកជនប្រមាណ៤០នាក់ ត្រូវបានជួបសម្ភាសន៍ផ្ទាល់ទៅតាមកម្រងបញ្ជីសំណួរដែលរៀបចំដោយអ្នកស្រាវជ្រាវយុវវ័យក្មេង។
- **ការពិភាក្សាក្រុម៖** ការពិភាក្សាក្រុមត្រូវបានរៀបចំនៅតាមសង្កាត់ទាំង៤នៃក្រុងកំពង់ចាម ដែលមានអ្នកចូលរួមសរុបប្រមាណ៣៥នាក់ ដែលពួកគេអញ្ជើញមកពីក្រុមចំរុះ ទោះបីពួកគេត្រូវបានសម្ភាសន៍លើទម្រង់បុគ្គលសាមញ្ញៗ ឬបុគ្គលសំខាន់ៗរួចហើយក៏ដោយ។
- **ការសង្កេតភូមិសាស្ត្រ និងឥរិយាបថអ្នកចូលរួម៖** ការសង្កេតគឺជាវិធីសាស្ត្របំពេញបន្ថែមក្រៅពីទម្រង់ទាំងបីខាងលើ ព្រោះថាទម្រង់នេះអាចជួយឲ្យអ្នកស្រាវជ្រាវយុវវ័យក្មេងអាចមានព័ត៌មានកាន់តែច្រើនសម្រាប់ជាជំនួយដល់ការសរសេរបាយការណ៍ស្រាវជ្រាវរបស់ពួកគេ។

**៣.៥ ទំហំគំរូសំណាក៖** ការស្រាវជ្រាវនេះត្រូវបានកំណត់សំណាកអ្នកចូលរួមតាមផែនការ និងគោលបំណង ហើយបុគ្គលត្រូវជួបសម្ភាសន៍ត្រូវបានកំណត់អត្តសញ្ញាណនិងជួបសម្ភាសន៍ដោយចៃដន្យ។ តាមផែនការ ការស្រាវជ្រាវនេះត្រូវបានកំណត់អ្នកចូលរួមចំនួន២០០នាក់ (៦០%ជាស្ត្រី) សម្រាប់ការសម្ភាសន៍បុគ្គលសាមញ្ញៗ

៤០នាក់សម្រាប់បុគ្គលសំខាន់ៗ និង ៣៥នាក់សម្រាប់៤ពិភាក្សាក្រុម ដែលអ្នកអ្នកទាំងនោះអញ្ជើញមកពីតំបន់គោលដៅ៤សង្កាត់នៃក្រុងកំពង់ចាម។

**៣.៦ ដំណើរការស្រាវជ្រាវ៖** ដំណើរការស្រាវជ្រាវនេះ ត្រូវបានអនុវត្តជាដំណាក់កាលដូចខាងកក្រោមនេះ

- ❖ មុនពេលចុះប្រមូលទិន្នន័យ៖ យុវជនស្រាវជ្រាវវ័យក្មេងត្រូវបានជ្រើសរើស បណ្តុះបណ្តាល និងតម្រង់ទិសពីការកំណត់បញ្ហាស្រាវជ្រាវ ការបង្កើតសំណួរ និងឧបករណ៍ស្រាវជ្រាវ ការរៀបចំផែនការ និងការសុំកិច្ចសហការណ៍ពីអាជ្ញាធរ និងអ្នកពាក់ព័ន្ធ និងសិក្សាលើឯកសារដែលមានសម្រាប់ដូចជាច្បាប់ គោលនយោបាយ និងរបាយការណ៍ស្រាវពាក់ព័ន្ធផ្សេងៗដែលពាក់ព័ន្ធទៅនឹងសំណួរស្រាវជ្រាវដែលបង្កើតឡើយដោយយុវជនជ្រាវជ្រាវវ័យក្មេង។
- ❖ ក្នុងពេលចុះប្រមូលទិន្នន័យ៖ យុវជនស្រាវជ្រាវវ័យក្មេងត្រូវបានលើកទឹកចិត្តឲ្យមានការទំនាក់ទំនងល្អ និងបន្តកិច្ចសាហាការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ និងធ្វើការត្រួតពិនិត្យលើការប្រមូលទិន្នន័យរបស់ក្រុមយុវជន ផ្ទៀងផ្ទាត់ និងឆ្លុះបញ្ចាំងលើដំណើរការប្រមូលទិន្នន័យ។
- ❖ ក្រោយពេលការចុះប្រមូទិន្នន័យ៖ យុវជនស្រាវជ្រាវវ័យក្មេងត្រូវបានលើកទឹកចិត្តឲ្យធ្វើការសម្អាតទិន្នន័យ វិភាគនិន្ន័យ សរសេរពង្រៀងរបាយការណ៍ស្រាវជ្រាវ រៀបចំជាបទបង្ហាញ និងកផលិតវីដេអូចំណេះដឹងផងដែរ ។

**ឧបករណ៍ប្រមូលទិន្នន័យ៖** ឧបករណ៍ប្រមូលទិន្នន័យត្រូវបានរៀបចំ និងចងក្រងជាពីរផ្នែក គឺ

- ❖ ទិន្នន័យបែបគុណភាព៖ កម្រងសំណួរបើកចំហ តារាងម៉ាទ្រីកស៏នៃភាពងាយគ្រោះ ប្រតិទិននៃពេលវេលា និងតាមរដូវកាល និងការវិភាគអ្នកពាក់ព័ន្ធត្រូវបានប្រើប្រាស់។
- ❖ ទិន្នន័យបែបបរិមាណ៖ កម្រងសំណួរបាទ-ទេ ទម្រង់៥ពន្ទុ និងពហុជម្រើស ត្រូវបានប្រើជាឧបករណ៍ចម្បងសម្រាប់ការប្រមូលទិន្នន័យ។

ឧបករណ៍ប្រមូលទិន្នន័យប្រកបដោយភាពច្នៃប្រឌិតត្រូវបានប្រើប្រាស់ទាំងអនឡាញ (Google Form) និងច្បាប់ចម្លងរឹង (Hard Copy) ដើម្បីងាយស្រួលដល់យុវជនស្រាវស្រាវវ័យក្មេងសម្រាប់ការប្រមូលព័ត៌មាន/ទិន្នន័យពីអ្នកឆ្លើយសំណួរស្រាវជ្រាវ នៅតាមតំបន់គោលដៅនៃក្រុងកំពង់ចាម។ ច្បាប់ចម្លងរឹងនៃកម្រងសំណួរដែលប្រើគឺដើម្បីកាត់បន្ថយអត្រានៃកំហុសនៅពេលដែលអ៊ីនធឺណិតមិនស៊ីសង្វាក់គ្នា ខណៈដែលអ្នកស្រាវជ្រាវវ័យក្មេងរបស់ CISA ប្រមូលព័ត៌មានសម្រាប់អ្នកសម្ភាសន៍នៅឆ្ងាយពីទីក្រុង/ក្រុង។ ឧបករណ៍ច្នៃប្រឌិតត្រូវបានរចនាឡើងដើម្បីពិចារណាករណីនៃការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនដែលមិនអាចទាក់ទងបា

ន។ សម្រាប់ដំណើរការប្រមូលព័ត៌មាន/ទិន្នន័យទាំងនោះ អ្នកប្រមូលទិន្នន័យត្រូវបានបណ្តុះបណ្តាល បង្ហាត់បង្ហាញ និងលើកទឹកចិត្តឲ្យអនុវត្តសម្ភាសន៍ទល់មុខគ្នាផ្ទាល់ជាមួយក្រុមគោលដៅ។

**៣.៧ ការធានាគុណភាពទិន្នន័យ និងការវិភាគទិន្នន័យ៖** ទិន្នន័យនៅក្នុងការស្រាវជ្រាវនេះត្រូវបានធានាគុណភាពរបស់វាជាមួយនឹងភាពជឿជាក់ និងសុពលភាពសម្រាប់ការវិភាគ និងរបាយការណ៍។ វិធីសាស្ត្រត្រីកោណក្នុងការស្រាវជ្រាវបានធ្វើឱ្យទិន្នន័យអាចជឿទុកចិត្តបានពីឯកសារផ្លូវការរបស់រដ្ឋាភិបាល និងលទ្ធផលស្រាវជ្រាវជាក់ស្តែង ជាការប្រមូលទិន្នន័យបន្ទាប់បន្សំ។ វិធីសាស្ត្រសម្រាប់ការប្រមូលទិន្នន័យបឋមបានអនុវត្តវិធីសាស្ត្រពិគ្រោះយោបល់ និងការចូលរួមពីក្រុមគោលដៅគម្រោង។ ការត្រួតពិនិត្យទិន្នន័យ និងការគាំទ្របានបញ្ជាក់ពីទិន្នន័យត្រឹមត្រូវ រួមទាំងការរចនាលក្ខខណ្ឌនៅក្នុងឧបករណ៍ប្រមូលទិន្នន័យពីក្រុមអ្នកប្រមូលទិន្នន័យ ។

អ្នកប្រមូលទិន្នន័យបានទទួលការកសាងសមត្ថភាពលើបច្ចេកទេសប្រមូលទិន្នន័យ និងការស្រាវ ជ្រាវប្រកបដោយក្រមសីលធម៌ តាមរយៈការបណ្តុះបណ្តាល ការធ្វើតេស្ត និងការបង្ហាត់បង្ហាញ។ ទិន្នន័យគុណភាពត្រូវបានកត់សម្គាល់ និងចម្លងសម្រាប់ការវិភាគជាការវិភាគខ្លឹមសារ និងសំយោគចេញពីចម្លើយចូលរួមពីអ្នកចូលរួមសម្ភាសន៍ និងការពិភាក្សាក្រុម។ ទិន្នន័យបរិមាណដែលបានយកចេញពីទម្រង់ Google សម្ភាត និងវិភាគតាមទម្រង់ Excel មុនពេលរបាយការណ៍ត្រូវបានសរសេរ ។

**៣.៨ ការឆ្លើយតបយេនឌ័រ និងបរិសាយប័ន្ននៅក្នុងដំណើរការប្រមូលទិន្នន័យ៖** ការឆ្លើយតបយេនឌ័រមានលំហូរនៅគ្រប់ដំហានទាំងមូលនៃការស្ទង់មតិ ឬការប្រមូលទិន្នន័យ។ ស្ត្រី បុរស អ្នករស់នៅជាមួយពិការភាព មនុស្សចាស់ អ្នកស្រលាញ់ភេទដូចគ្នា ក្រុមជនជាតិដើម និងក្រុមមនុស្សងាយរងគ្រោះត្រូវបានរួមបញ្ចូលនៅក្នុងដំណើរការទាំងមូលនៃការស្ទង់មតិ ឬការប្រមូលទិន្នន័យ ដូចជានៅក្នុងការរចនាការស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ ចងក្រងកម្រងសំណួរ ផែនការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ស្រាវជ្រាវ។ របាយការណ៍ស្ទង់មតិនឹងកំណត់បាននូវតម្រូវការអាទិភាព ឱកាសនៃការរួមចំណែកដ៏មានសក្តានុពល បញ្ហាប្រឈមសំខាន់ៗ ការណែនាំប្រកបដោយប្រសិទ្ធភាពដោយការត្រួតពិនិត្យសមភាពយេនឌ័រ និងការរួមបញ្ចូលសង្គម។

**៣.៩ រចសម្ព័ន្ធនៃវិធីសាស្ត្រស្រាវជ្រាវ៖** ដំណើរការស្រាវជ្រាវនេះ ត្រូវបានអនុវត្តដោយក្រុមយុវជនស្រាវជ្រាវវ័យក្មេងដែលត្រូវបានចងក្រង និងបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវដោយផ្ទាល់ពីអង្គការសម្ព័ន្ធដើម្បីសុរឹតភាព និងគណនេយ្យភាពសង្គម (CISA)។

រូបភាពទី១៖ រចនាសម្ព័ន្ធនៃដំណើរការស្រាវជ្រាវ

ការស្រាវជ្រាវដែលមានការចូលរួម

↓

ទិន្នន័យបន្ទាប់បន្សំ ← ដំណើរការ → ទិន្នន័យបឋម

ការស្វែងរកឯកសារដែលមានស្រាប់៖

- នៅសាលាក្រុងកំពង់ចាម អង្គការនានា និង
- តាមអ៊ីនធឺណេត

ការបង្កើតឧបករណ៍ស្រាវជ្រាវ

ការប្រមូលទិន្នន័យ

ការសរសេរបាយការណ៍

ការធ្វើបទបង្ហាញ

ការអនិវត្តផ្ទាល់តាមរយៈ៖

- ការជួបសម្ភាសន៍ និងការពិភាក្សាក្រុមជាមួយក្រុមគោលដៅ
- ការសង្កេតពីភូមិសាស្ត្រ

## ៤.ប្រជាសាស្ត្រ និងភូមិសាស្ត្រ



ក្រុងកំពង់ចាមមាន៤សង្កាត់ និង ៣១ភូមិ ដែលស្ថិតនៅជាប់ដងទន្លេមេគង្គ ត្រើយខាងលិច តភ្ជាប់ទៅត្រើយខាងកើតទន្លេមេគង្គ នៃស្រុកត្បូងឃ្មុំរបស់ខេត្តត្បូងឃ្មុំ ដោយស្ពានគីហ្សូណា ដែលជាជំនួយឥតសំណងរបស់ប្រទេសជប៉ុន ហើយស្ពាននេះអាចសម្រួលដល់ការធ្វើដំណើរ ទៅបណ្តាលខេត្តនានាដូចជា ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរី។ សង្កាត់ទាំង៤ ក្នុងក្រុងកំពង់ចាម រួមមាន សង្កាត់បឹងកុក សង្កាត់កំពង់ចាម សង្កាត់សំបួរមាស និងសង្កាត់វាលវង់ ។

**ក្រុងកំពង់ចាម** គឺជាទីរួមខេត្តនៃខេត្តកំពង់ចាមនៅភាគខាងកើតនៃប្រទេសកម្ពុជា។ ក្រុងនេះជាទីក្រុងធំជាងគេលំដាប់ទី១២ ក្នុងប្រទេសកម្ពុជា ដែលមានប្រជាជនចំនួន ៦១,៧៥០នាក់ (ទិន្នន័យឆ្នាំ២០២១) ហើយមានទីតាំងនៅលើដងទន្លេមេគង្គ។ ខេត្តកំពង់ចាមមានចម្ងាយ១២៤គីឡូម៉ែត្រភាគឦសានពីរាជធានីភ្នំពេញ ហើយអាចទៅបានដោយទូក ឬតាមផ្លូវកៅស៊ូ។ ដោយត្រូវចំណាយពេលប្រហែល ២,៥ ម៉ោងតាមរថយន្ត ឬ ៣,៥ ម៉ោង

តាមទូក ពីភ្នំពេញទៅក្រុងកំពង់ចាម។ ទីក្រុងនេះត្រូវបានតភ្ជាប់ទៅស្រុកត្បូងឃ្មុំ ដោយស្ពានគីហ្សូណា ដែលជាស្ពានទីមួយក្នុងប្រទេសកម្ពុជា ដែលលាតសន្ធឹងតាមដងទន្លេមេគង្គ។

# ៥.លទ្ធផលស្រាវជ្រាវ

## ៥.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម

ក្នុងអំឡុងពេលនៃការប្រមូលទិន្នន័យរបស់ក្រុមយុវជនសហគមន៍ មានប្រជាពលរដ្ឋ ឬបុគ្គលសាមញ្ញៗចំនួន ១៨០នាក់ បានចូលរួម ក្នុងនោះមានស្រីចំនួន៦៧% ប្រុសចំនួន៣១% និងLGBTQI+ ចំនួន២% ដោយឡែកអ្នកពាក់ព័ន្ធដែលជាបុគ្គលសំខាន់ៗជាមន្ត្រីសង្កាត់ សាលាក្រុង ការិយាល័យពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងស្ថាប័នវិស័យឯកជននានា មានចំនួន៤០នាក់ ស្រីចំនួន៤៥% និងប្រុស៥៥% បន្ទាប់ពីទិន្នន័យត្រូវបានសម្អាត។ អ្នកចូលរួមទាំងអស់គឺត្រូវបានជួបសម្ភាសន៍ដោយផ្ទាល់ដោយក្រុមយុវជនសហគមន៍មកពីសង្កាត់ទាំង៤ក្នុងក្រុងកំពង់ចាម។ ហើយក្នុងចំណោម១៨០នាក់នៃបុគ្គលសាមញ្ញៗមានខ្មែរឥស្លាមចំនួន៤% និងជនពិកាចំនួន៤% ដោយឡែកក្រុមបុគ្គលសំខាន់ៗក៏មានជនពិកា៣%ផងដែរត្រូវបានជួមសម្ភាសន៍។

**រូបភាពទី២ និងទី៣៖** ភេទ និងក្រុមជាតិសាសន៍របស់អ្នកចូលរួមឆ្លើយសំណួរសម្ភាសន៍







ក្រុមគោលដៅនៅតាមសង្កាត់ទាំង៤ ដែលយុវជនស្រាវជ្រាវបានជួបសម្ភាសន៍ជាមួយមានអាយុចន្លោះពី១៥ ទៅ១៨ឆ្នាំ ចំនួន៦% អាយុចន្លោះពី១៩ ទៅ២៤ឆ្នាំមានចំនួន១០% អាយុចន្លោះពី២៥ ទៅ៣០ឆ្នាំមានចំនួន១២% និងមានចំនួន៥%សម្រាប់បុគ្គលសាមញ្ញៗ អាយុចន្លោះពី៣១ ដល់៣៥ឆ្នាំ មានចំនួន១៥% រីឯបុគ្គលសំខាន់ៗមានចំនួន១៨% និងអាយុចន្លោះពី៣៦ឆ្នាំឡើងទៅ មានចំនួន៥៧% និងបុគ្គលសំខាន់ៗមានចំនួន៧៧%។ អ្នកចូលរួមទាំងអស់មកពីវិស័យឯកជនចំនួន៤៤% សម្រាប់បុគ្គលសាមញ្ញៗ និង១៤% សម្រាប់បុគ្គលសំខាន់ៗ មកពីរដ្ឋាភិបាលមានចំនួន ២% សម្រាប់បុគ្គលសាមញ្ញៗ និងមានចំនួន២០%សម្រាប់បុគ្គលសំខាន់ៗ មកពីអង្គការសង្គមស៊ីវិលមានចំនួន២% សម្រាប់បុគ្គលសាមញ្ញៗ និងមានចំនួន១៣%សម្រាប់បុគ្គលសំខាន់ៗ មកពីអាផ្ទាធ

រមូលដ្ឋានមានចំនួន៥៣% សម្រាប់តែបុគ្គលសំខាន់ៗ និងមកពីប្រជាសហគមន៍មានចំនួន៥២%សម្រាប់តែបុគ្គលសាមញ្ញៗ ។

| អ្នកចូលរួម | វិស័យឯកជន | សង្គមស៊ីវិល | រដ្ឋាភិបាល | សហគមន៍/អាជ្ញាធរ |
|---|---|---|---|---|
| បុគ្គលសាមញ្ញៗ | ៤៤% | ២% | ២% | ៥២% |
| បុគ្គលសំខាន់ៗ | ១៤% | ១៣% | ២០% | ៥៣% |

**រូបភាពទី៤ និងទី៥៖** អាយុ និងការងាររបស់អ្នកចូលរួមឆ្លើយសំណួរសម្ភាសន៍







### ៥.២ ការយល់ដឹងរបស់យុវជន និងប្រជាសហគមន៍អំពីអភិបាលកិច្ចមូលដ្ឋាន

យោងតាមសេចក្តីណែនាំអំពីអភិបាលកិច្ចល្អ ពាក្យថា **អភិបាលកិច្ចមូលដ្ឋាន** គឺជាការអនុវត្តនូវសិទ្ធិ ឬអំណាចនយោបាយ សេដ្ឋកិច្ច រដ្ឋបាល ឬអ្វីផ្សេងទៀតដើម្បីគ្រប់គ្រងកិច្ចការ និងធនធាននៅកម្រិតមូលដ្ឋាន។ ហើយពាក្យថា **អភិបាលកិច្ចល្អ** នៅកម្រិងមូលដ្ឋាន គឺមានន័យថា មានសមត្ថភាពគ្រប់គ្រងកិច្ចការ និងធនធាន នៅមូលដ្ឋាន ប្រកបដោយឆន្ទៈ មានលក្ខណៈបើកចំហរ តម្លាភាព គណនេយ្យភាព សមធម៌ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធផល។

ជាប្រវត្តិសាស្ត្រ ពិសេសបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ គេបានចាត់ទុកការងារគ្រប់គ្រងរដ្ឋក្នុងប្រទេសមួយជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ ក្របខ័ណ្ឌនយោបាយប្រជាធិបតេយ្យរបស់រដ្ឋាភិបាលបានស្នើរសុំឲ្យមានមុខងារឯករាជ្យ បីរយ៉ាងដែលមានការទាក់ទងគ្នាទៅវិញទៅមក គឺនីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ។ក្នុងសង្គមខុសៗគ្នារយៈពេលជា៦០ឆ្នាំកន្លងមកនេះ មុខងារទាំងនេះត្រូវបានរៀបចំផ្សេងៗគ្នាទោះបីជានៅក្រោគោលបំណងរួមក៏ដោយ។

ដោយមានការកើនឡើងនូវការបាត់ការទុកចិត្តពីប្រជាជនសាមញ្ញ ទៅលើស្ថាប័នរដ្ឋាភិបាល និងដោយសមត្ថភាពរបស់ស្ថាប័នទាំងនោះ ក្នុងការឆ្លើយតបចំពោះផលប្រយោជន៍ និងការរំពឹងទុកច្រើនយ៉ាងរបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះ ជាមួយនឹងភាពលំអៀងរវាងគោលនយោបាយរបស់រដ្ឋាភិបាល និងការអនុវត្តកាន់តែរីកធំឡើងស្របគ្នានឹងការកើនឡើងនូវគម្លាតរវាងអ្នកក្រ និងប្រជាពលរដ្ឋដែលគេមិនអើពើពីស្ថាប័នរដ្ឋាភិបាលរួមទាំងបញ្ហានៃភាពក្រីក្រដែលរកទីបញ្ចប់គ្មាន ការផាត់ចោល និងការមិនអើពើនៅប្រទេសជាច្រើនក្នុងពិភពលោក និងដោយមានការកើនឡើងនូវសារៈសំខាន់ខាងផលប្រយោជន៍ជំនួញឯកជន គោលគំនិតនៃការគ្រប់គ្រងឥឡូវនេះបានចាប់ផ្តើមដូរទៅជាទ្រឹស្តីអភិបាលកិច្ចវិញ។ ទោះបីជាយ៉ាងណាក៏ដោយក្នុងអត្ថន័យកម្រិតបឋមនៃវិស័យអភិបាលកិច្ចល្អ គឺទាក់ទងនឹងដំណើរពេញលក្ខណៈរបស់រដ្ឋ និងស្ថាប័នរបស់ខ្លួន និងការលើកស្ទួយសមធម៌ និងយុត្តិធម៌សង្គម។

ធនាគារពិភពលោក គឺជាអ្នកនាំយកទស្សនៈអំពី "អភិបាលកិច្ចល្អ" ចូលទៅក្នុងកិច្ចការអភិវឌ្ឍន៍មុនគេក្នុងប៉ុន្មានទស្សវត្តកន្លងទៅនេះ។ បទពិសោធន៍របស់ធនាគារ ចំពោះភាពបរាជ័យនៃគោលនយោបាយសេដ្ឋកិច្ចក្នុងបណ្តាប្រទេសអាហ្វ្រិក ធ្វើឲ្យធនាគារទម្លាក់ការបរាជ័យនេះទៅលើ "អភិបាលកិច្ចមិនល្អ" មានដូចជាអប្រសិទ្ធផលខាងផ្នែករដ្ឋបាល អំពើពុករលួយ ការខ្វះតម្លាភាព.....។ល។ ក្នុងប្រទេសទាំងនេះ។ ការបង្កើតចេញជាគោលគំនិតអំពីអភិបាលកិច្ចមិនល្អ បាននាំឲ្យមានការរៀបចំគោលគំនិតអំពីអភិបាលកិច្ចល្អ ដែលដាក់បញ្ចូលវិស័យជាច្រើនដូចជាប្រសិទ្ធផលខាងផ្នែករដ្ឋបាល នីតិរដ្ឋ ការទទួលខុសត្រូវ និងតម្លាភាព។ ទោះជាយ៉ាងណា ក៏ដោយ ធនាគារមិនបានដាក់"អភិបាលកិច្ចល្អ" ឲ្យពាក់ព័ន្ធជាមួយនឹងរបបនយោបាយជាក់លាក់ណាមួយទេ។ ការពាក់ព័ន្ធរវាង "អភិបាលកិច្ចល្អ" និងលទ្ធិប្រជាធិបតេយ្យមានការជំរុញយ៉ាងជាក់លាក់ណាមួយទេ។ ការពាក់ព័ន្ធរវាង"អភិបាលកិច្ចល្អ" និងលទ្ធិប្រជាធិបតេយ្យ មានការជំរុញយ៉ាងជាក់ស្តែងឲ្យចូលទៅក្នុងការងារអភិវឌ្ឍន៍តាមរយៈភ្នាក់ងារផ្តល់ជំនួយទ្វេភាគី ដោយបង្កើតនូវលក្ខខណ្ឌជំនួយ ដើម្បីឲ្យមានការបោះឆ្នោតជាទៀងទាត់ការលើកស្ទួយសិទ្ធិមនុស្សនិងនីតិរដ្ឋ។

UNDP ចាត់ទុកអភិបាលកិច្ចល្អ ថាជាអត្តិភាពនៃកិច្ចការរបស់ស្ថាប័នរដ្ឋាភិបាល រួមជាមួយច្បាប់ និងបទបញ្ញត្តិក្នុងការរួមគ្នាបង្កើត និងការពារបរិស្ថានសង្គម និងប្រព័ន្ធអេកូឡូស៊ីដែលជាមូលដ្ឋាននៃការអភិវឌ្ឍរបស់មនុស្សនិងសម្រាប់ក្រុមទាំងអស់នៅក្នុងសង្គម។ ដូច្នេះអភិបាលកិច្ចល្អ គឺជាសំណុំរឿងមួយរបស់អភិបាលកិច្ច ដែលធនធានសាធារណៈ និងបញ្ហាផ្សេងៗ ត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាព ប្រសិទ្ធផល និងឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម។ ដូច្នេះការចូលរួមរបស់សាធារណជន ក្នុងការដាក់ឥទ្ធិពលលើការសម្រេចចិត្ត តម្លាភាព និងការទទួលខុសត្រូវ គឺជាចំណុចចម្បងៗ/សញ្ញាសម្គាល់នៃអភិបាលកិច្ចល្អ (UNDP ឆ្នាំ ១៩៩៧)។

របាយការណ៍របស់RFI ចុះថ្ងៃទី០៦ ខែកម្ភៈ ឆ្នាំ២០១៧ បានរាយការណ៍ថា ក្រសួងមហាផ្ទៃបានត្រួតពិនិត្យ និងវាយតម្លៃពីស្ថានភាពអភិបាលកិច្ចមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ គឺមានការ

កើនឡើងតែ៦ភាគរយតែប៉ុណ្ណោះ ហើយក្នុងនោះ ផ្នែកខ្លះមានការធ្លាក់ចុះថែមទៅទៀត។ ហេតុដូច្នេះ ទើបអភិបាលកិច្ចថ្នាក់ក្រោមជាតិ នៅតែមានកម្រិតទាប និងនៅតែមានកង្វល់។

ការវាស់វែងអំពីស្ថានភាពនៃអភិបាលកិច្ចមូលដ្ឋាន នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយក្រសួងមហាផ្ទៃ គឺធ្វើឡើងបីឆ្នាំម្ដង។ ការវាយតម្លៃការអង្កេតនេះ គឺផ្អែកលើ៨ចំណុចៈ ១. ការចូលរួមរបស់ប្រជាពលរដ្ឋ ២. តម្លាភាព និងការរាយការណ៍ ៣. គណនេយ្យភាព ៤. អន្តរដ្ឋបាល ៥. ការបន្ស៊ីផ្នែកគោលនយោបាយ ៦. ការឆ្លើយតប ៧.ការគាំទ្រក្រុមជនងាយរងគ្រោះ និង ៨. ការផ្ដល់សេវា។

ជាក់ស្ដែង ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ គឺស្របពេលនឹងការផ្ដើមការធ្វើកំណែទម្រង់ស៊ីជម្រៅរបស់រដ្ឋាភិបាលដែរ គឺសន្ទស្សន៍អភិបាលកិច្ចមូលដ្ឋាន ក្នុងរយៈពេលនេះ កើនឡើងបានតិចតួចតែប៉ុណ្ណោះ គឺត្រឹម៦ភាគរយ។ហើយតាមការអង្កេតរបស់ស្ថាប័នរដ្ឋខ្លួនឯងដដែល គឺបានទទួលស្គាល់ថា ការបន្ស៊ីផ្នែកគោលនយោបាយ ការចូលរួមរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាព មានការធ្លាក់ចុះ។

ចំពោះសន្ទស្សន៍អភិបាលកិច្ចមូលដ្ឋាន មានការកើនឡើងតិចតួច និងមានផ្នែកខ្លះក៏ធ្លាក់ចុះ ក្នុងឆ្នាំកន្លងទៅនេះ គឺត្រូវអ្នកវិភាគខាងអភិបាលកិច្ចល្អ មើលឃើញពីមូលហេតុ គឺដោយសារតែឧបសគ្គរាំងស្ទះ ភាពសកម្ម និងភាពចន្លោះប្រហោងមួយចំនួន។

របាយការណ៍ RFI ដ៏ដែលបាននិយាយថា បញ្ហានាំមុខគេ គឺអំពើពុករលួយតែម្ដង ដែលនៅតែបន្តស៊ីរូងក្នុងប្រព័ន្ធរដ្ឋបាល និងស្ថាប័នសាធារណៈរបស់ជាតិ ពិសេសគឺនៅតែបន្តមានអំពើពុករលួយ ទោះតិចឬច្រើនក្តី នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ តាមរបាយការណ៍របស់អង្គការតម្លាភាពអន្តរជាតិ ដែលចេញកាលពីប៉ុន្មានសប្ដាហ៍មុននេះ គឺជាអំណះអំណាងស្រាប់ គឺថាកម្ពុជាជាប់លេខ១៥៦ ក្នុងចំណោមប្រទេស១៧៦លើពិភពលោក ហើយកម្ពុជាគឺពុករលួយខ្លាំងជាងគេបង្អស់នៅតំបន់អាស៊ាន។

ទន្ទឹមនេះ ចំពោះអំពើពុករលួយក្នុងថ្នាក់មូលដ្ឋាននៅស្រុកខ្មែរ គឺមានកត្តាជាច្រើនដែលពាក់ព័ន្ធគ្នា បើទោះបីជាមានយន្តការកំណែទម្រង់ជាច្រើនមកហើយក្តី។ បញ្ហានេះ គឺជាជំងឺដុះស្លែ ជាមួយនឹងប្រព័ន្ធរដ្ឋបាលដែលចាស់គំរឹល ប្រព័ន្ធការងារថ្នាក់ក្រោមជាតិយូរឆ្នាំ រួមទាំងមន្ត្រីបម្រើសេវាកម្មនោះទៀតសោត សុទ្ធតែអ្នកកាន់ការងារចាស់វស្សាថែមទៀត។ មន្ត្រីថ្នាក់ក្រោម ដែលចាស់ៗ គឺធ្លាប់មានទម្លាប់ចាស់ដែរ រឿងយកថ្លៃទឹកតែ ឬថ្លៃទឹកប៊ិចជាដើម។

បញ្ហារាំងស្ទះក្នុងការធ្វើឲ្យអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ដើរលឿនទៅមិនរួចនោះ គឺទំនងជាអាចមកពីខ្វះខាតធនធានមនុស្ស ដែលសម្បូរចំណេះដឹងនិងសមត្ថភាព ព្រមទាំងភាពច្នៃប្រឌិតបង្កើតថ្មី ក្នុងការផ្ដល់សេវានៅមូល

ដ្ឋាន។ ផ្ទុយទៅវិញ យុវជន និងធនធានមនុស្សដែលចេះដឹងជំនាន់ថ្មី ហាក់គិតតែចង់សម្រុកមកថ្នាក់ជាតិ គឺមិនចង់ធ្វើការនៅថ្នាក់មូលដ្ឋានប៉ុន្មានឡើយ។

បញ្ហានេះ ក៏ជាប់ពាក់ព័ន្ធនឹងធនធានថវិកាផងដែរ រាប់ទាំងថវិកាសម្រាប់អភិវឌ្ឍសេវាអភិបាលកិច្ចថ្នាក់ក្រោមជាតិ រួមទាំងថវិកាសម្រាប់ប្រាក់បៀវត្សរបស់ពួកគេ នៅមានកម្រិតទាបនៅឡើយ។ ដូច្នេះ គឺលំបាកនឹងយកអ្នកចេះដឹងខ្លាំង ទៅធ្វើការនៅមូលដ្ឋានណាស់។

ឧបសគ្គចម្បងមួយទៀត គឺប្រព័ន្ធការងារថ្នាក់ក្រោមជាតិ ត្រូវរង់ចាំស្តាប់បញ្ជាទាំងស្រុងពីថ្នាក់លើ ថ្នាក់ជាតិដែលចាំតែចេញបញ្ជា គឺធ្វើឲ្យរដ្ឋបាលថ្នាក់មូលដ្ឋាន គ្មានស្វ័យភាពនៃការសម្រេចចិត្ត បើទោះបីជាថ្នាក់ក្រោមនោះ គិតថាល្អ ឬត្រឹមត្រូវក៏ដោយ ក៏មិនហ៊ានធ្វើដែរ។ ដូច្នេះដំណើរការនៃការស្នើយោបល់ និងការសម្រេចចេញបញ្ជា គឺត្រូវស៊ីពេល និងធ្វើឲ្យយឺតយ៉ាវការងារយ៉ាងប្រាកដ។

លើសពីនេះ គឺមានការបែងចែកអំណាចនៃការសម្រេចចិត្តនិងអំណាចក្នុងការងារ មិនទាន់ត្រឹមត្រូវ។ អ្នកជំនាញអភិបាលកិច្ច កត់សម្គាល់ឃើញថា រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រសួងក្តី ច្រើនតែទម្លាក់ការងារនិងការទទួលខុសត្រូវ ទៅថ្នាក់មូលដ្ឋាន ប៉ុន្តែមិនទម្លាក់អំណាច និងទម្លាប់កញ្ចប់ថវិកាសមរម្យសម្រាប់អនុវត្តនោះទេ។ ហើយពេលខ្លះ គឺរង់ចាំតែបន្ទោសថ្នាក់ក្រោមទៀតផង។

ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីរួមចំណែកកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋាភិបាលកម្ពុជា បានបង្កើតការិយាល័យច្រកចេញចូលតែមួយ។ នេះគឺជាផ្នែកសំខាន់នៃវិមជ្ឈការអំណាច ឲ្យការផ្តល់សេវាកាន់តែខិតជិតប្រជាពលរដ្ឋ។ ការិយាល័យច្រកចេញចូលតែមួយ គឺជាមានក្រសួងចំនួន១១ ដែលបានធ្វើប្រតិភូកម្មមុខងារ។ វាបានន័យថា ផ្ទេរភារៈកិច្ចក្នុងការផ្តល់សេវារដ្ឋបាល ដល់ថ្នាក់រដ្ឋបាលក្រុង ស្រុក និងខណ្ឌ។

ជាមួយគ្នានេះ អង្គការមូលនិធិអាស៊ី តាមរយៈគម្រោងគំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់ កាលពីខែធ្នូឆ្នាំ២០១៦ បានរកឃើញថា កម្ពុជាមានកំណែទម្រង់៣សំខាន់នៅក្នុងចំណោមក្រសួងទាំង១៧ នៅឆ្នាំ២០១៦ គឺវិស័យអប់រំ ការប្រមូលពន្ធដារ និងការផ្គត់ផ្គង់ទឹកស្អាត។ ក៏ប៉ុន្តែ ការស្ទង់មតិ គេរកឃើញថា ពលរដ្ឋខ្មែរភាគច្រើនមិនទទួលបានព័ត៌មានពីការធ្វើកំណែទម្រង់របស់រដ្ឋាភិបាលនោះទេ។ ដូច្នេះ នៅក្នុងដំណើការកែទម្រង់ថ្នាក់ក្រោមជាតិ ជួបបញ្ហារាំងស្ទះរៀបរាប់ទាំងនេះ និងគឺនៅតែជាឧបសគ្គដដែល។ រឿងនេះ នឹងអាចធ្វើឲ្យស្ថានភាពអភិបាលកិច្ចមូលដ្ឋាន ឡើងបន្តិច ឬធ្លាក់ជាគំហុក ក៏អាចថាបាន។

**ពិនិត្យលើបាឆាតខាងក្រោម យើងឃើញថា ទាំងយុវជន និងប្រជាសហគមន៍មានការយល់ដឹងស្តីពីអភិបាលកិច្ចមូលដ្ឋានគិតជាមធ្យម គឺមាន៦២% មិនយល់ដឹងសោះ មាន២៥.១%បានយល់ដឹងតិចតួច មាន៨.៩%បាន**

យល់ដឹងជាបង្គួរ មាន៣.៦%យល់ដឹងបានល្អ។ ចំនួនភាគរយគិតជាមធ្យមនៅត្រង់នេះ គឺវាស់វែងលើអថេរចំនួន៥ គឺ គោលការណ៍នៃអភិបាលកិច្ចល្អ កត្តាដែលនាំឲ្យមានសង្គមល្អ ការកំណត់អត្តសញ្ញាណនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាននិងការចូលរួមក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាននានា។ បើយោងតាមសៀវភៅណែនាំបច្ចេកទេសពីគណៈកម្មាធិការជាតិដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ សម្រាប់អត្ថន័យនៃពាក់ទាំង៥លើ មានន័យថា៖

**១. គោលការណ៍នៃអភិបាលកិច្ចល្អ៖** ភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។ ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP 1997) បានអោយនិយមន័យថា "អភិបាលកិច្ចល្អ ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស"។ គោលការណ៍នៃអភិបាលកិច្ចល្អមាន៩ ចំណុច គឺ ការចូលរួម នីតិរដ្ឋ តម្លាភាព ការព្រមព្រៀងឯកភាពគ្នា សមធម៌ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ គណនេយ្យភាព ការឆ្លើយតប ចក្ខុវិស័យជាយុទ្ធសាស្ត្រ។ ដកស្រង់ចេញពីសៀវភៅអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ។




**២. កត្តាដែលនាំឲ្យមានសង្គមល្អ៖** សរុបមតិអ្នកចូលរួមបានបង្ហាញថា សង្គមល្អ គឺជាសង្គមដែលរីកចម្រើន មានសន្តិភាព និងសុវត្ថិភាព ហើយវាអាស្រ័យលើកត្តា អ្នកដឹកនាំល្អ សាមគ្គីភាពផ្ទៃក្នុងប្រទេសការដឹកនាំប្រើយុទ្ធសាស្ត្រសមស្រប ស្ថានភាពប្រទេស ពលរដ្ឋគ្រប់រូបមានចិត្តជាតិនិយម ការគោរពច្បាប់របស់ពលរដ្ឋក្នុងសង្គម និងចេះប្រើប្រាស់ធនធានរបស់ប្រទេស រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិភាពខ្ពស់។




យោងតាមឯកសារបច្ចេកទេសស្តីពីអភិបាលកិច្ចល្អបានបង្ហាញកត្តាដែលនាំឲ្យមានសង្គមល្អ គឺការផ្តល់សេវាដែលឆ្លើយតមទៅនឹង ១).តម្រូវការមូលដ្ឋាន ដូចជាបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច ការអប់រំ និងហេដ្ឋារចនាសម្ព័នជាដើម ២).ការចូលរួមៈ សំដៅដល់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងដំណើរការអភិបាលកិច្ចល្អ ការសម្រេចចិត្ត ការត្រួតពិនិត្យ និងតាមដានលើការអនុវត្តផែនការ និងថវិកាជាតិ និង៣).ការចងក្រងគ្នាជាក្រុម សំដៅដល់ការគោរពនិងឲ្យតម្លៃលើសិទ្ធិ សេរីភាព លទ្ធិប្រជាធិបេត្យ វប្បធម៌ អរយ្យេធម៌ និងប្រពៃណីយ៍ជាតិ ។

**៣. ការកំណត់អត្តសញ្ញាណនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋានៈ** តាមឯកសារបច្ចេទេសស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលចេញដោយលេខាធិការដ្ឋាន គជអប ឆ្នាំ ២០១៤ បាននិយាយថា ការចូលរួមរបស់ប្រជាពលរដ្ឋមានន័យមិនត្រឹមតែដើម្បីជាការប្រមូលព័ត៌មាន ការស្តាប់យោបល់គ្រឡប់ និងទទួលសំណូមពរពីប្រជាពលរប៉ុណ្ណោះទេ ប៉ុន្តែការចូលរួមរបស់ប្រជាពល គឺដើម្បីបានបង្កើននូវកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋក្នុងដំណើរការ នៃការធ្វើផែនការ និងការស្រេមចចិត្ត។ ការប្រមូលព័ត៌មាន និងការចូលរួមរបស់ប្រជាពលរដ្ឋ គឺមានទំនាក់ទំនងគ្នាទៅវិញមក។ បើគ្មានការប្រមូលព័ត៌មានទេ ក្រុមប្រឹក្សាពុំអាចដឹងបានស៊ីជម្រៅលើបញ្ហាណាមួយ ត្រូវការកិច្ចសហប្រតិបត្តិការ និងត្រូវការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋតាមរយៈការពិគ្រោះយោបល់ និងការផ្តល់មតិយោបល់ផ្សេងៗ។

**៤. ការកំណត់អត្តសញ្ញាណនៃពលរដ្ឋសកម្មៈ** នៅវេទិកាយុវជនជាច្រើនដែលរៀបចំដោយសង្គមស៊ីវិលបានបង្ហាញថា ប្រជាពលរដ្ឋសកម្មគឺជាចំណុចចាប់ផ្តើម និងជាកម្លាំងដ៏រឹងមាំនៃការអភិវឌ្ឍប្រទេស។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងនឹងការលើកឡើងពីការជំរុញឲ្យយុវជនមានភាពសកម្មក្នុងការចូលរួមឈឺឆ្អាលពីបញ្ហាសង្គមនេះ យុវជនមួយចំនួន បានលើកឡើងនូវសំនួរស្រដៀងគ្នាដែលថា ពួកគេមានការព្រួយបារម្ភចំពោះការបង្ក្រាបពួកគេ នៅពេលដែលពួកគេ និងពលរដ្ឋផ្សេងទៀតប្រមូលផ្តុំគ្នាចូលរួមការពារប្រយោជន៍សង្គមដូចជាការធ្វើបាតុកម្មទាមទារសិទ្ធិសេរីភាព និងយុត្តិធម៌ ចូលរួមការពារព្រៃឈើ តវ៉ារឿងព្រំដែន និងប្រយោជន៍សាធារណៈផ្សេងៗទៀត។ ឆ្លើយតបនឹងសំនួរស្តីពីការព្រួយបារម្មណ៍នេញ យុវជនត្រូវបានលើកទឹកចិត្តឲ្យប្រកាន់ជំហរដដែលថា យុវជនត្រូវតែព្យាយាមបន្តទាមទារនូវសិទ្ធិសេរីភាព និងអ្វីដែលជាប្រយោជន៍ប្រទេសជាតិ ដោយមិនចុះចាញ់ តែត្រូវធ្វើដោយភាពឆ្លៃប្រឌិត និងសន្តិវិធី ជៀសវាងពាក្យអសុរោះ ការជេរប្រមាថនិងការរើសអើង។

**៥.ការចូលរួមក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋានៈ** យោងតាមឯកសារផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (ផអ៣) (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម

ជាតិរយៈពេលឆ្នាំ(២០១០-២០១៩) ទំព័រ១៦ ចំណុច៤.៣.២ និងឯកសារពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា៖

- ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាមធ្យោបាយដ៏សំខាន់មួយដែលសមាជិកក្រុមប្រឹក្សាជាប់ឆ្នោតអាចទទួលបានព័ត៌មានពីតម្រូវការរបស់ប្រជាពលរដ្ឋ និងសហគមន៍ ព្រមទាំងស្តាប់ និងទទួលយកនូវមតិយោបល់ ឬគំនិតផ្សេងៗ (ដោយរួមទាំងមតិយោបល់ ទាំងគំនិតដែលមានលក្ខណៈផ្ទុយគ្នា) នៅក្នុងដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា។
- ការចូលរួមរបស់ប្រជាពលរដ្ឋ គឺមិនត្រឹមតែជាការស្តាប់នូវមតិយោបល់របស់ប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែជាដំណើរការទទួលខុសត្រូវរួមគ្នា ដែលតាមរយៈដំណើរការនេះ ក្រុមប្រឹក្សាមានកាតព្វកិច្ចពន្យល់ និងបកស្រាយនូវសេចក្តីសម្រេចនានារបស់ខ្លួនជូនដល់ប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនវិញ។
- ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាដំណើរការដែលតម្រូវឲ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិត្រូវជួបប្រាស្រ័យទាក់ទងជាប្រចាំជាមួយប្រជាពលរដ្ឋ ក្រុមទទួលផល សង្គមនស៊ីវិល តាមរយៈការប្រជុំក្នុងកិច្ចប្រជុំជាសាធារណៈ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ និងវេទិកាផ្សេងៗ។
- ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាកត្តាគន្លឹះនៃអភិបាលកិច្ចល្អ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើនឱកាសក្រកបដោយការលើកទឹកចិត្ត និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋអាចធ្វើសកម្មភាព ស្របទៅតាមផលប្រយោជន៍របស់ខ្លួន និងផលប្រយោជន៍រួមដោយគ្មានការរឹតត្បិត ឬភ័យក្លាចពីការរើសអើងផ្សេងៗ។

ដោយឡែកសម្រាប់ការយល់ដឹងរបស់ប្រជាសហគមន៍ស្តីពីអត្ថន័យអាភិបាលកិច្ចមូលដ្ឋានថា ពួកគេបានរៀបរាប់ថា អភិបាលកិច្ចល្អគឺជាដំណើរការនៃការគ្រប់គ្រងមូលដ្ឋានប្រកបដោយការទទួលខុសត្រូវ និងមានការចូលរួមតាមបែបវិធីសាស្ត្រនិងមធ្យោបាយជាវិជ្ជមានដែលរដ្ឋាភិបាល អាជ្ញាធរ ស្ថាប័ន និងអង្គភាពរដ្ឋប្រើប្រាស់ដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច ធនធាន និងសន្តិសុខសហគមន៍ ឬប្រទេសជាតិដើម្បីបំរើ និងផ្តល់ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋស្របតាមគោលការណ៍នៃការចូលរួម តម្លាភាព គណនេយ្យភាព នីតិរដ្ឋ ប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមព្រៀងឯកភាព និងការឆ្លើយតប។ អ្នកដឹកនាំអនុវត្តស្របតាមគោលការណ៍អភិបាលកិច្ចល្អ គឺពួកគេចេះជួយប្រជាពលរដ្ឋ និងមើលការខុសត្រូវអំពីជីវភាពរស់នៅ និងជួយដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋប្រកបដោយគុណធម៌ សមធម៌ សច្ចធម៌ និងយុត្តិធម៌ ។

បាហ្រ្កាហ្វខាងក្រោមបង្ហាញអំពីកំរិតនៃការយល់ដឹងរបស់មនុស្សវ័យក្មេង និងប្រជាសហគមន៍ស្តីពីអភិបាលកិច្ចមូលដ្ឋាន គិតជាមធ្យមភាគមានកំរិតមិនយល់សោះ មានចំនួន៦២% យល់ដឹងតិចតួច មាន២៥.១% យល់ដឹងជាបង្គួរ មាន៨.៩% យល់ដឹងបានល្អ មាន៣.៦% និងយល់ដឹងបានល្អណាស់ មាន០.៣%។

## រូបភាពទី៦៖ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីអភិបាលកិច្ចមូលដ្ឋាន

| | និយមន័យនៃអភិបាលកិច្ចល្អ | កត្តាដែលនាំឲ្យមានសង្គមល្អ | ការកំណត់អត្តសញ្ញាណនៃការចូលរួម | ការកំណត់អត្តសញ្ញាណពលរដ្ឋសកម្ម | ការចូលរួមធ្វើផែនការអភិវឌ្ឍន៍នានា | មធ្យមភាគ |
|---|---|---|---|---|---|---|
| យល់ដឹងល្អណាស់ | 0.0% | 0.0% | 0.0% | 1.7% | 0.0% | 0.3% |
| យល់ដឹងបានល្អ | 2.2% | 3.9% | 4.0% | 4.0% | 4.0% | 3.6% |
| យល់ដឹងជាបង្គួរ | 7.9% | 13.5% | 5.7% | 10.9% | 6.3% | 8.9% |
| យល់ដឹងតិចតួច | 14.5% | 36.5% | 18.3% | 39.7% | 16.7% | 25.1% |
| មិនយល់ដឹង | 75.4% | 46.1% | 72.0% | 43.7% | 73.0% | 62.0% |

យល់ដឹងល្អណាស់ យល់ដឹងបានល្អ យល់ដឹងជាបង្គួរ យល់ដឹងតិចតួច មិនយល់ដឹង

បើពិនិត្យមើលលើបាឆាតខាងក្រោម វាមានអថេរចំនួន៤ត្រូវបានលើកមកបង្ហាញ គឺអថេរនិយាយអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការអនុវត្តផែនការអភិវឌ្ឍ និងផែនការថវិការបស់ក្រុមប្រឹក្សាសង្កាត់និងក្រុង។ យើងអាចពិនិត្យឃើញថា កំរិតនៃការយល់ដឹងគិតជាមធ្យមមានអ្នកមិនយល់សោះ មាន៧៦.១% អ្នកយល់ដឹងតិចតួច មាន១៣.៩% អ្នកដល់ដឹងជាបង្គួរ មាន៦.៨% អ្នកយល់ដឹងបានល្អ មាន៣.០% និងអ្នកយល់ដឹងបានល្អណាស់ មាន០.៣%។

## រូបភាពទី៧៖ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការអនុវត្តផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាសង្កាត់និងក្រុង

| | មិនយល់ដឹង | យល់ដឹងតិចតួច | យល់ដឹងជាបង្គួរ | យល់ដឹងបានល្អ | យល់ដឹងល្អណាស់ |
|---|---|---|---|---|---|
| មធ្យមភាគ | 76.1% | 13.9% | 6.8% | 3.0% | 0.3% |
| ការធ្វើថវិកាអភិវឌ្ឍន៍ក្រុង | 86.1% | 9.2% | 3.5% | 0.6% | 0.6% |
| ការធ្វើផែនការអភិវឌ្ឍន៍ក្រុង | 80.0% | 10.9% | 6.9% | 2.2% | 0.0% |
| ការធ្វើថវិកាអភិវឌ្ឍន៍សង្កាត់ | 69.8% | 16.5% | 9.7% | 3.4% | 0.6% |
| ការធ្វើផែនការអភិវឌ្ឍន៍សង្កាត់ | 68.4% | 19.0% | 6.9% | 5.7% | 0.0% |

មធ្យមភាគ ការធ្វើថវិកាអភិវឌ្ឍន៍ក្រុង ការធ្វើផែនការអភិវឌ្ឍន៍ក្រុង ការធ្វើថវិកាអភិវឌ្ឍន៍សង្កាត់ ការធ្វើផែនការអភិវឌ្ឍន៍សង្កាត់

## ៥.៣ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់និងក្រុង

ការអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យ និងមានការទទួលខុសត្រូវ ស្ថាប័នទាំងនោះត្រូវធ្វើជាតំណាង និងឆ្លើយតបចំពោះតម្រូវការនានារបស់ប្រជាពលរដ្ឋ គឺជាគោលបំណងចម្បងមួយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដោយសារអភិបាលកិច្ចល្អបានរួមចំណែកយ៉ាងធំធេងក្នុងដំណើរការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវលើកកម្ពស់ការអនុវត្តនូវគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ ដោយត្រូវធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋបានចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចនោះ ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាផងដែរ។

នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសកម្ពុជា ការធ្វើគណនេយ្យភាពត្រូវបានអនុវត្តតាមរបៀបខុសៗគ្នា ប៉ុន្តែមានគោលបំណង ដូចគ្នា។ ចាប់តាំងពីឆ្នាំ២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋរបស់ខ្លួន នៅរៀងរាល់៥ឆ្នាំម្តងៗ។ ចាប់តាំងពីឆ្នាំ២០០៩ ក្រុមប្រឹក្សារាជធានី ខេត្តក្រុង ស្រុកខណ្ឌ ក៏ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅរៀងរាល់៥ឆ្នាំម្តងផងដែរ។ ផ្អែកតាមច្បាប់រៀបចំអង្គការ ក្រុមប្រឹក្សាត្រូវបំពេញមុខងារជាតំណាងប្រជាពលរដ្ឋនៅក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ព្រមទាំងធ្វើការត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដែលបានដាក់ចេញផងដែរ។

គណៈអភិបាលមានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីចាត់ចែងកិច្ចការរដ្ឋបាល និងត្រួតពិនិត្យមើលកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ គណៈអភិបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ក្នុងការអនុវត្តនូវសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា។ ក្នុងការអនុវត្តជាក់ស្តែង ទោះបីមានការរីកចម្រើនជាច្រើនក៏ដោយក៏ប៉ុន្តែសមត្ថភាពរបស់ក្រុមប្រឹក្សានៅកំរិតឃុំសង្កាត់ និងស្រុកក្រុង នៅក្នុងការអនុវត្តសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ និងការត្រួតពិនិត្យមើលពីលើនៅមានកម្រិតនៅឡើយ។

ក្រុមប្រឹក្សាឃុំ សង្កាត់មានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រចាំជាមួយប្រជាពលរដ្ឋរបស់ខ្លួន។ ដោយឡែក ក្រុមប្រឹក្សារាជធានី ខេត្តក្រុង ស្រុកខណ្ឌពុំសូវមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រចាំជាមួយប្រជាពលរដ្ឋឡើយ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពខ្ពស់។ ទោះបីយ៉ាងនេះក៏ដោយ ក៏រដ្ឋបាល ថ្នាក់ក្រោមជាតិនៅតែមានគណនេយ្យភាពចំពោះក្របខ័ណ្ឌច្បាប់ដោយត្រូវគោរពតាមគោលការណ៍ នីតិវិធី និងបទដ្ឋាននៃការផ្តល់សេវាដែលកំណត់ដោយ

ក្រសួង ស្ថាប័ននានា។ បច្ចុប្បន្នសេចក្តីណែនាំពាក់ព័ន្ធនឹងរបៀបចាត់ចែង គ្រប់គ្រង និងពង្រឹងការអនុវត្តតាមរយៈដំណើរការធ្វើអធិការកិច្ច កំពុងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

យោងតាមមាត្រា៣៤ ផ្នែកទី២ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និងអភិបាល៉។

ជាមួយគ្នានេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិទាមទារឲមានការបង្កើតនូវខ្សែគណនេយ្យភាពថ្មី ការលើកកម្ពស់ការយល់ដឹង និងការបង្កើតប្រព័ន្ធ នីតិវិធី និងយន្តការទាំងឡាយដើម្បីធានាថា សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារ សំឡេងប្រជាពលរដ្ឋត្រូវបានដឹងឮ និងធនធាននានាត្រូវបានប្រើប្រាស់ស្របតាមច្បាប់។

តាមន័យនេះ ការពង្រឹងការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកត្តាគន្លឹះមួយក្នុងការធានាឲការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទទួលបានជោគជ័យស្របតាមទស្សនវិស័យ ដូចដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ គណនេយ្យភាព ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន អាស្រ័យតាមស្ថានភាពជាក់ស្តែង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅក្នុង បរិបទនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គណនេយ្យភាព ត្រូវបានកំណត់និយមន័យស្រដៀងៗគ្នាដូចខាងក្រោម ៖

- សៀវភៅកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិកំណត់ថា "គណនេយ្យភាព គឺជាកាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ" ។
- សៀវភៅផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ ឆ្នាំ២០១៥-២០១៧នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ផអ៣ទី២) បានកំណត់ថា "គណនេយ្យភាព គឺជាកាតព្វកិច្ចនៃអ្នកអនុវត្ត សិទ្ធិអំណាចក្នុងការឆ្លើយ បំភ្លឺអំពីសកម្មភាព នានារបស់ខ្លួនចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែល អាចដាក់នូវពិន័យក្នុងករណីខកខានមិនបានអនុវត្ត។
- សៀវភៅអភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៥ កំណត់ថា "គណនេយ្យភាព គឺជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត

នោះ ដោយមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន រាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត"។

គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ សំដៅលើការអនុវត្តគណនេយ្យភាពរបស់អង្គដែលកើតឡើងពីការបោះឆ្នោត (ដោយផ្ទាល់ ឬ ប្រយោល) ចំពោះប្រជាពលរដ្ឋទូទៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍ ៖ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សា ក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដែលកើតចេញពីការបោះឆ្នោត ត្រូវមានគណនេយ្យភាពចំពោះប្រជាពល-រដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គោលបំណងនៃការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បី ៖

- ធានាឲ្យមានប្រសិទ្ធភាពនៃការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបម្រើឆន្ទៈ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាឲ្យមានភាពជាតំណាងសាធារណៈយ៉ាងពិតប្រាកដ
- ធានាឲ្យមានប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- និងពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍមូលដ្ឋាន។

គណនេយ្យភាពចំពោះប្រជាពលរដ្ឋ សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការរៀបចំឱ្យមានវិធានការ យន្តការ និងនីតិវិធីនានាសម្រាប់ធានាឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ដូចគ្នានឹងគណនេយ្យភាពពីលើទៅក្រោម ឬគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពី ជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្ដីសម្រេច ដោយធានាបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយក្រុមប្រឹក្សាក៏ត្រូវទទួលខុសត្រូវរាល់សេចក្ដីសម្រេច និងការអនុវត្តសេចក្ដីសម្រេចរបស់ខ្លួនផងដែរ។ ឧទាហរណ៍៖ ក្រុមប្រឹក្សាឃុំ គឺអង្គដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំដែលកើតចេញពីការបោះឆ្នោតនេះ មានភារកិច្ចចម្បងក្នុងការចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្ដីត្រូវការនានារបស់ប្រជាពលរដ្ឋ។

ក្នុងការអនុវត្តតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាឃុំ "គ" បានអនុម័តដីកាស្ដីពីការប្រើប្រាស់បឹងធម្មជាតិ ដោយត្រូវហាមឃាត់រាល់សកម្មភាពប្រើប្រាស់ថ្នាំពុលគីមីកសិកម្មនៅជុំវិញមាត់បឹង ដែលអាចនឹងបង្កផលប៉ះពាល់ដល់គុណភាពទឹក និងសត្វដែលរស់នៅក្នុងទឹកបឹង។ ដីកាដែលបានដាក់ឲអនុវត្តនេះ បានធ្វើឲកសិករដាំបន្លែជុំវិញបឹងមិនសប្បាយចិត្ត ហើយបានមកតវ៉ានៅមុខសាលាឃុំ។ មេឃុំ "គ" បានធ្វើការឆ្លើយបំភ្លឺជូនប្រជាកសិករទាំងនោះដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ និងសម-ហេតុផល ដែលអាចឲកសិករទាំងនោះទទួលយកបាន។ តាមរ

យៈការប្ដឹងតវ៉ានេះ ឃុំអាចរកដំណោះស្រាយសមស្របតាមមធ្យោបាយផ្សេងៗទៀតសម្រាប់អ្នកដែលទទួលផលប៉ះពាល់នេះ។

គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះរាជរដ្ឋាភិបាល សំដៅទៅលើ គណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ឬរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដែលប្រតិបត្តិនៅថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័នសាមី។ គណនេយ្យភាពប្រភេទនេះ អាចហៅបានម្យ៉ាងទៀតថា គណនេយ្យភាពខ្សែបណ្ដោយ។ ឧទាហរណ៍ថាក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។ ក្រៅពីប្រភេទគណនេយ្យភាពដូចបានរៀបរាប់ខាងលើ ក៏នៅមាន ប្រភេទគណនេយ្យភាពផ្សេងៗទៀត ដូចជា ៖

១. គណនេយ្យភាពផ្នែករដ្ឋបាល៖ សំដៅលើគណនេយ្យភាព ដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រង នីតិវិធីស្តង់ដារ និងនិយាមការងាររបស់បុគ្គល និងអង្គការចាត់តាំងតាមឋានានុក្រម។

២. គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ៖ សំដៅទៅលើគណនេយ្យភាព ដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ស្របទៅតាមច្បាប់ និងគោលការណ៍ហិរញ្ញវត្ថុ។

៣. គណនេយ្យភាពសង្គម៖ គណនេយ្យភាពសង្គមសំដៅលើ សកម្មភាព ឬយន្តការនានា ដែលប្រជាពលរដ្ឋអាចប្រើប្រាស់ ដើម្បីទាមទារឲ្យរដ្ឋមានគណនេយ្យភាពចំពោះខ្លួន ព្រមទាំងសកម្មភាពនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល និងតួអង្គដទៃទៀត ក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាព និងយន្តការទាំងនោះ។

តាមន័យនេះ គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក៏ជាមធ្យោបាយមួយ ដែលបន្ស៊ីគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវផ្ដល់ឱកាសឲប្រជាពលរដ្ឋ និងតំណាងរបស់ពួកគាត់អាចការពារនូវផលប្រយោជន៍របស់ខ្លួន និងពិនិត្យតាមដានលើការបំពេញការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និងអ្នកផ្ដល់សេវាកម្មនានាដែលនៅមូលដ្ឋាន។ គណនេយ្យភាពសង្គម ក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានគោលបំណងផ្ដល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានាក្នុងការចូលរួមពង្រឹងការចាត់ចែងការប្រើប្រាស់ថវិកា និងការផ្ដល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយស្រួលទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និង ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. គណនេយ្យភាពផ្នែកច្បាប់ ៖ សំដៅទៅលើគណនេយ្យភាពចំពោះមុខច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ដើម្បីពង្រឹងការអនុវត្តគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ និង បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈតាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- ការបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ នៅថ្នាក់ក្រោមជាតិ តម្រូវឲ្យបង្កើតនូវយន្តការមួយដែលត្រូវមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- បង្កើតស្ថាប័ននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលមានតំណាងជាប់ឆ្នោត ដើម្បីជួយលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ សំដៅលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការនៅមូលដ្ឋាន និងអនុញ្ញាតឲមូលដ្ឋានធ្វើការសម្រេចចិត្ត ប្រកាន់យកជម្រើសនានាទាក់ទងនឹងការអភិវឌ្ឍមូលដ្ឋាន ដែលមានគណនេយ្យភាពលើការធ្វើសេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួន។
- នៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបង្កើតឲមានក្រុមប្រឹក្សាមួយ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដើម្បីធានាដល់កិច្ចដំណើរការការងាររបស់ថ្នាក់រដ្ឋបាលទាំងនោះ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ដូច្នេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ គឺជាអង្គដែលកើតចេញពីការបោះឆ្នោត ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ដែលនៅកៀកប្រជាពលរដ្ឋ និងដែលមានតួនាទីចម្បងក្នុងការធានាឲមានប្រសិទ្ធភាពខ្ពស់បំផុតនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្នុងមាត្រា៤១បានចង្អុលបង្ហាញឲរដ្ឋបាលឃុំ សង្កាត់ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីក្នុងការជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។ តាមន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឲមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពីការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួន ស្របតាមគោលការណ៍អភិបាលកិច្ចល្អដែលបានកំណត់។

ដើម្បីធានាដល់ការអនុវត្តគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីការគ្រង់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានកំណត់អំពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ជានាបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណាដែលខ្លួនយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ និងត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និងអភិបាល (មាត្រា ៣៤)។
- ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិ-បាល និងអភិបាល។ ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬអភិបាល និងបុគ្គល ដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា (មាត្រា១៥៧)។
- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិ-បត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា (មាត្រា៣៥)។

យោងតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក បានកំណត់កាន់តែលម្អិតអំពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ខ្លឹម-សារសំខាន់ៗទាំងនោះ មានដូចជា ៖

- ក្រុមប្រឹក្សាខេត្តត្រូវសហការជាមួយក្រុមប្រឹក្សាក្រុងស្រុកក្នុងខេត្តរបស់ខ្លួន ដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្តរបស់ខ្លួន ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ (មាត្រា១៨៥នៃអនុក្រឹត្យលេខ២១៦)។
- ដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះប្រជាពលរដ្ឋរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឱ្យមានយន្តការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក សំដៅជានាឱ្យបានថា ជម្រើសសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកមានការឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក និងប្រជាពលរដ្ឋទាំងអស់ក្នុងស្រុករបស់ខ្លួន (មាត្រា១១៦នៃអនុក្រឹត្យលេខ២១៦)។
- ក្រុមប្រឹក្សាស្រុកអាចធ្វើការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីប្រើប្រាស់នូវបុគ្គលិករបស់រដ្ឋបាលស្រុក ដើម្បីជួយគាំទ្រធនធានផ្នែករដ្ឋបាល និងផ្នែកសមត្ថភាពដល់រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់តាមការចាំបាច់។ បុគ្គលិករបស់ស្រុកដែលចាត់ឱ្យជួយគាំទ្រខាងលើនេះ ត្រូវមានគណនេយ្យភាព អំពីសកម្មភាពរបស់ខ្លួនចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែល ខ្លួនគាំទ្រ ហើយត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុកអំពីការគោរព និងការអនុវត្តភារកិច្ចស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា (មាត្រា១២៤នៃអនុក្រឹត្យលេខ២១៦)។

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់យោបល់ ពិគ្រោះយោបល់ និងត្រួត-ពិនិត្យ ដើម្បីធានាថាក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុកនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត (មាត្រា១៨៥នៃអនុក្រឹត្យលេខ២១៦)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមាន (មាត្រា១៨៥នៃអនុក្រឹត្យលេខ២១៦)។
- ក្រុមប្រឹក្សាស្រុក ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុក អំពីជម្រើស សេចក្តីសម្រេច ការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្តីសម្រេច និងការអនុវត្តទាំងនោះ (មាត្រា១៨៤នៃអនុក្រឹត្យលេខ២១៦)។

ក្រៅពីលិខិតបទដ្ឋានគតិយុត្តខាងលើ ក៏នៅមានឯកសារគោលនយោបាយ និងឯកសារកម្មវិធីផ្សេងៗទៀតបានកំណត់អំពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដូចជា ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឯកសារកម្មវិធីជាតិ និងឯកសារផអ៣ ដំណាក់កាលទី១ និងទី២ជាដើម។

ក្នុងការឆ្លើយតបទៅនឹងឆន្ទៈ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា អំពីការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវពង្រឹងការអនុវត្តគណនេយ្យភាពរបស់ខ្លួន។ ដូច្នេះ ដើម្បីធានាឲមានការអនុវត្តគណនេយ្យភាពនៅក្នុងរដ្ឋបាលរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពង្រឹង ៖

- គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ
- គណនេយ្យភាពរបស់រដ្ឋបាល (អ្នកផ្តល់សេវា) ចំពោះ ប្រជាពលរដ្ឋ
- គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះរាជរដ្ឋា ភិបាល

ដើម្បីធានាឲមានគណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ឬគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំយន្តការ និងមធ្យោបាយសមស្របនានាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួនប្រកបដោយតម្លាភាព ការពិគ្រោះយោបល់ និងការទទួលបានព័ត៌មានគ្រប់គ្រាន់ ព្រមទាំងទទួលបាននូវព័ត៌មាន ឬពាក្យបណ្តឹង ត្រឡប់ពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីសេចក្តីសម្រេចរបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗគប្បីពិចារណា និងប្រមូលបញ្ហា តម្រូវការ និងមតិយោបល់របស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដើម្បីឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចដឹងអំពីបញ្ហា តម្រូវការ ការបារម្ភ និងមតិយោបល់ ឬសំឡេងរបស់ប្រជាពលរដ្ឋដែលត្រូវបានយកចិត្តទុកដាក់ ក្រុមប្រឹក្សាត្រូវបង្កើតឱ្យមានយន្តការ ឬវិធីសាស្ត្រនានាសម្រាប់ការប្រាស្រ័យទាក់ទងជាទៀងទាត់រវាងមន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ យន្ត

ការ ឬ វិធីសាស្ត្រមួយចំនួន សម្រាប់ប្រមូលបាននូវបញ្ហា តម្រូវការ និងមតិយោបល់ ឬសំឡេងរបស់ប្រជាពលរដ្ឋ អាចមានដូចជា ៖

- **ការផ្សព្វផ្សាយព័ត៌មាន៖** ក្រុមប្រឹក្សាត្រូវចាត់ចែងឲរដ្ឋបាលរបស់ខ្លួនធ្វើការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ជាមួយគ្នានេះ ក្រុមប្រឹក្សាក៏ត្រូវធ្វើការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ អំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងគណៈ-កម្មាធិការនានារបស់ក្រុមប្រឹក្សា និងអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិជូនសាធារណជនផងដែរ។ ក្រៅពីនេះ ក្រុមប្រឹក្សាក៏ត្រូវធានាផងដែរថា រាល់ព័ត៌មាននានាពាក់ព័ន្ធនឹងការអនុវត្តការងាររបស់រដ្ឋបាលខ្លួនត្រូវបានផ្សព្វផ្សាយជាសាធារណៈ (លើកលែងតែ ព័ត៌មានមួយចំនួនដែលត្រូវហាមឃាត់ការផ្សព្វផ្សាយជាសាធារណៈ)។
- **ការរៀបចំកិច្ចប្រជុំ៖** រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ និងមានការចូលរួមពីប្រជាពលរដ្ឋទាំងបុរស ស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមប្រឹក្សាប្រភេទដូចគ្នា ក្រុមប្រឹក្សាប្រភេទផ្សេងគ្នា មន្ទីរ អង្គភាព ការិយាល័យ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត។ ដើម្បីធានាឲមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងកិច្ចប្រជុំ ក្រុមប្រឹក្សាត្រូវធានាថា ៖
    - ប្រតិទិនប្រចាំឆ្នាំនៃការប្រជុំរបស់ក្រុមប្រឹក្សាត្រូវបានផ្សព្វផ្សាយជាសាធារណៈ
    - កម្មវិធីប្រជុំជាក់លាក់នីមួយៗរបស់ក្រុមប្រឹក្សាត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយបញ្ជាក់យ៉ាងច្បាស់លាស់អំពីពេលវេលា ទីកន្លែង និងសេចក្តីព្រាងរបៀបវារៈជាដើម
    - ទីកន្លែងប្រជុំបានបង្កលក្ខណៈងាយស្រួលដល់អ្នកចូលរួមក្នុងការសង្កេត និងបញ្ចេញមតិយោបល់
    - ក្រៅពីផ្សព្វផ្សាយឲមានការចូលរួមពីសាធារណជនទូទៅ លិខិតអញ្ជើញចូលរួមកិច្ចប្រជុំត្រូវបានរៀបចំសម្រាប់ក្រុម ឬបុគ្គលជាក់លាក់ដែលត្រូវអញ្ជើញឲចូលរួមពិភាក្សា ផ្តល់យោបល់លើប្រធាន បទជាក់លាក់ (តាមសេចក្តីព្រាងរបៀបវារៈ) និងត្រូវធានាផងដែរថា លិខិតអញ្ជើញនោះបានបញ្ជូនដល់អ្នកទាំងនោះស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ល។
- **ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ៖** ក្រុមប្រឹក្សាត្រូវ រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រចាំឆ្នាំរបស់ខ្លួន ដែលតាមរយៈវេទិកានេះ ក្រុមប្រឹក្សាអាចជម្រាបអំពីសកម្មភាព និងលទ្ធ-ផលសម្រេចបានក្នុងឆ្នាំកន្លងទៅ និងបង្ហាញអំពីផែនការសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ដើម្បីពិភាក្សាជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់។ លើសពីនេះទៀត វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ ផ្តល់ឱកាសឲរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធ្វើការប្រាស្រ័យទាក់-ទងគ្នាទៅវិញទៅមកជាមួយប្រជាពលរដ្ឋ

អង្គការសង្គមស៊ីវិល វិស័យឯកជន ព្រមទាំងទទួលយកនូវសំណើ សំណូមពរ ការព្រួយបារម្ភ បំណងប្រាថ្នានានា ដែលជាតម្រូវការរបស់ពួកគេ ដើម្បីធ្វើការដោះ-ស្រាយ និងឆ្លើយតប។ ដើម្បីធានាថា ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ត្រូវបានរៀបចំឡើង និងទទួលបានលទ្ធផលល្អ ក្រុមប្រឹក្សាត្រូវធានាថា ៖

- ព័ត៌មានពាក់ព័ន្ធនឹងការរៀបចំវេទិកានេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមមធ្យោបាយផ្សព្វផ្សាយនានាដែលប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មានទាំងនោះដោយងាយស្រួល
- ប្រជាពលរដ្ឋ (បុរស ស្ត្រី កុមារា កុមារី ជនងាយរងគ្រោះ...) ក្រុមប្រឹក្សាពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវបានអញ្ជើញឲ្យចូលរួម
- ប្រជាពលរដ្ឋ និងអ្នកចូលរួមទាំងអស់មានឱកាសគ្រប់គ្រាន់ក្នុងការបញ្ចេញមតិយោបល់
- រាល់សំណើ សំណូមពរ និងយោបល់ទាំងអស់ត្រូវបានកត់ត្រា និងលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាដើម្បីចាត់វិធានការដោះស្រាយនិងឆ្លើយតបតាមរយៈការដោះស្រាយ ឬតាមរយៈការបកស្រាយប្រកបដោយភាពសមហេតុផល និងអាចទទួលយកបាន។

❖ **ការរៀបចំវេទិកាដទៃទៀត៖** ក្រៅពីរៀបចំវេទិកាផ្សព្វផ្សាយ និង ពិគ្រោះយោបល់ប្រចាំឆ្នាំខាងលើ ក្រុមប្រឹក្សាអាចរៀបចំវេទិកាផ្សេងៗទៀតសម្រាប់ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដូចជា វេទិកាពិគ្រោះយោបល់អំពីការរៀបចំផែនការអភិវឌ្ឍន៍ វេទិកាអំពីការរៀបចំដីកា វេទិកាទាក់ទងនឹងការប្រើប្រាស់ថវិកាជាដើម។ តាមរយៈវេទិកាទាំងនេះ ក្រុមប្រឹក្សា ឬបុគ្គលិកក្រុមប្រឹក្សាអាចស្តាប់អំពីបញ្ហាតម្រូវ-ការ និងសំណូមពររបស់ប្រជាពលរដ្ឋរបស់ខ្លួន ហើយក៏ជាវេទិកាសម្រាប់ក្រុមប្រឹក្សា ឬបុគ្គលិករបស់ក្រុមប្រឹក្សាក្នុងការឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនផងដែរ។

❖ **ការរៀបចំយន្តការសម្រាប់ទទួល និងផ្តល់ព័ត៌មាន៖** ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គួររៀបចំឲមានយន្តការជាក់លាក់សម្រាប់ទទួល និងផ្តល់ព័ត៌មាននៅរដ្ឋបាលរបស់ខ្លួន ដូចជា ៖

- នៅថ្នាក់រាជធានី ខេត្ត ៖ រាជធានី ខេត្តមានក្រុមមន្ត្រីទទួលបន្ទុក ព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត។ ក្រុមមន្ត្រីទទួលបន្ទុកព័ត៌មាននេះមានតួនាទីជាអ្នកនាំពាក្យ និងជាមន្ត្រីទំនាក់ទំនងសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត។
- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ៖ ក្រុង ស្រុក ខណ្ឌគួរពង្រឹងការអនុវត្ត តួនាទីរបស់ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្នុងការអនុវត្តការងារផ្សព្វផ្សាយ និងទទួលព័ត៌មានពីសាធារណជននៅក្នុង ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ ដោយឡែកចំពោះ ក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយ ត្រូវពង្រឹងការអនុវត្តយន្តការដែលបានបង្កើត ដូចជា ពង្រឹងការអនុវត្តម៉ោងជួបប្រជាពលរដ្ឋ ការរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈប្រចាំឆមាស ការរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន និងការរៀបចំវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំជាដើម។

- នៅថ្នាក់ឃុំ សង្កាត់ ៖ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់មេភូមិតាមភូមិនីមួយៗនៃឃុំ សង្កាត់ដើម្បីបម្រើការងារជាអ្នកទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយនឹងប្រជាពលរដ្ឋ។ ក្រៅពីមេភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពង្រឹងគណៈកម្មាធិការនានាដែលបានបង្កើតឡើង ពិសេស គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដែលគណៈកម្មាធិការនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងនារី និងកុមារក្នុងឃុំ សង្កាត់។

កំណត់សម្គាល់៖ផ្អែកតាមបទពិសោធន៍នៃការអនុវត្តម៉ោង ជួបប្រជាពលរដ្ឋរបស់ការិយាល័យច្រកចេញចូលតែមួយ ដើម្បីពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ (ក្រៅពីក្រុង ស្រុក ខណ្ឌដែលមានការិយាល័យច្រកចេញចូលតែមួយ) គួររៀបចំឲ្យមានកាលវិភាគសម្រាប់ម៉ោងជួបប្រជាពលរដ្ឋ ដោយកំណត់យកថ្ងៃណាមួយនៃសប្តាហ៍ ដូចជា រៀងរាល់ថ្ងៃច័ន្ទជាដើម។

**ការរៀបចំបញ្ជីឈ្មោះទំនាក់ទំនង៖** ក្រុមប្រឹក្សាត្រូវចាត់ឲនាយករដ្ឋបាលរបស់ខ្លួនក្នុងការរៀបចំបញ្ជីឈ្មោះសម្រាប់ឲប្រជាពលរដ្ឋ អាច ទំនាក់ទំនងដោយផ្ទាល់មករដ្ឋបាលរបស់ខ្លួន។ បញ្ជីឈ្មោះទំនាក់ទំនងនេះ គួរបញ្ចូលនូវឈ្មោះ មុខតំណែង លេខទូរស័ព្ទ (ដូចមានក្នុងតារាងបញ្ជីគំរូ)។ សមាសភាពដែលគួរបញ្ចូលក្នុងបញ្ជីនេះ រួមមាន ប្រធានក្រុមប្រឹក្សា គ្រប់សមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងបុគ្គលិកផ្សេងទៀតតាមការចាំបាច់។

បន្ទាប់ពីរៀបចំបញ្ជីនេះរួច នាយករដ្ឋបាលត្រូវចាត់ចែងធ្វើការផ្សព្វផ្សាយឲបានទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងត្រូវបិទផ្សាយជាប្រចាំនៅលើក្តារព័ត៌មាននៅមុខសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

- **ការពង្រឹងការប្រើប្រាស់ប្រអប់សំបុត្រគណនេយ្យភាព៖** ប្រអប់សំបុត្រគណនេយ្យភាព បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលព័ត៌មានអំពីបញ្ហាប្រឈមនានាក្នុងការអនុវត្តមូលនិធិឃុំ សង្កាត់។ នាពេលខាងមុខដ៏ខ្លី ប្រអប់សំបុត្រគណនេយ្យភាពនេះ អាចនឹងជួយប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តមូលនិធិក្រុង ស្រុក និងការអនុវត្តថវិការបស់រាជធានី ខេត្តផងដែរ។ ប្រអប់សំបុត្រគណនេយ្យភាព គឺជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងអំពីការអនុវត្តរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ តាមរយៈប្រអប់សំបុត្រគណនេយ្យភាព រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចដឹងអំពីបញ្ហាតម្រូវការ និងការមិនពេញចិត្តនានារបស់ប្រជាពលរដ្ឋ។ ដូច្នេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះ អាចធ្វើការកែលម្អនូវការអនុវត្តរបស់ខ្លួន ឬអាចចាត់វិធានការដោះស្រាយ និង ឬអាចឆ្លើយតបចំពោះប្រជាពលរដ្ឋបានប្រកបដោយប្រសិទ្ធភាព។
- **ការទទួលយកការតវ៉ារបស់ប្រជាពលរដ្ឋ ឬក្រុមប្រជាពលរដ្ឋ៖** ការ ប្តឹងតវ៉ារបស់ប្រជាពលរដ្ឋ ឬក្រុមប្រជាពលរដ្ឋ គឺជាកញ្ចក់សម្រាប់ ឆ្លុះបញ្ចាំងអំពីការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ប្រសិនបើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាផ្តល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋ នោះប្រជាពលរដ្ឋនឹង

មិនធ្វើការតវ៉ាឡើយ។ ប៉ុន្តែប្រសិនបើ ការសម្រេច និងការអនុវត្តសេចក្តីសម្រេចចិត្តណា ដែលផ្តល់ផលប៉ះពាល់ជាអវិជ្ជ-មានដល់ពួកគាត់ នោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំងនេះនឹងធ្វើការតវ៉ា។ ដូច្នេះ ក្រុមប្រឹក្សា គណៈអភិបាលត្រូវស្វាគមន៍ចំពោះការតវ៉ាទាំងនោះ ហើយត្រូវពិចារណាដោះស្រាយ ឬឆ្លើយតបទៅប្រជាពល-រដ្ឋវិញប្រកបដោយភាពសមហេតុផល និងអាចទទួលយកបានពីសំណាក់ អ្នកទទួលផលប៉ះពាល់ទាំងនោះ។

- ផ្តល់ការអនុញ្ញាតឱ្យប្រជាពលរដ្ឋ អាចពិនិត្យឯកសារសំខាន់ៗរបស់ក្រុមប្រឹក្សានៅការិយាល័យនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចស្នើសុំ ថតចម្លងឯកសារនានារបស់ក្រុមប្រឹក្សាបាន (លើកលែងឯកសារសម្ងាត់ ឬឯកសារដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីកម្រិតនៃការផ្សព្វផ្សាយជាសាធារណៈ)។
- ដាក់បញ្ចូល និងតែងតាំងតំណាងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិលជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មការ ឬក្រុមការងារ ចំពោះកិច្ចនានា ដោយផ្តល់នូវតួនាទីសមស្រប មិនមែនត្រឹមតែជាអ្នកសង្កេតការណ៍ ឬអ្នកប្រឹក្សាយោបល់ឡើយ។
- រៀបចំយន្តការផ្សេងៗទៀតតាមការចាំបាច់ ដើម្បីធានាថា ប្រជាពលរដ្ឋ ទាំងបុរស ស្ត្រី និងក្រុមជនងាយរងគ្រោះមានឱកាសក្នុងការបញ្ចេញមតិយោបល់លើកឡើងអំពីបញ្ហា តម្រូវការ ការតវ៉ារបស់ខ្លួន ហើយក្រុមប្រឹក្សាអាចដឹង និងកត់ត្រានូវរាល់បញ្ហា តម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងបានពិចារណា និងចាត់វិធានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។

**ការឆ្លើយតបរបស់ក្រុមប្រឹក្សា៖** បន្ទាប់ពីទទួលបានព័ត៌មាន សំណួរ ការស្នើសុំការបំភ្លឺ ឬការបារម្ភរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវចាត់ចែងធ្វើការឆ្លើយតបឲបានយ៉ាងលឿនបំផុតតាមដែលអាចធ្វើទៅបាន។ ការឆ្លើយតបអាចធ្វើ តាមរយៈ ៖

- ការស្រាយបំភ្លឺ ការឆ្លើយ ឬការបញ្ជាក់អំពីមូលហេតុនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ ប្រកបដោយភាពសមហេតុផល និងអាចទទួលយកបានពីសំណាក់ប្រជាពលរដ្ឋ និងអ្នករងផលប៉ះពាល់។ ជាការប្រសើរ ការស្រាយបំភ្លឺគួរធ្វើឡើងយ៉ាងយូរក្នុងរយៈពេល០១សប្តាហ៍បន្ទាប់ពីទទួលបានព័ត៌មាន។ ការស្រាយបំភ្លឺ ឬការឆ្លើយតបរបៀបនេះអាចធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ៖
  - ការឆ្លើយតបដោយផ្ទាល់មាត់ ៖ អាចធ្វើឡើងតាមរយៈការជួបដោយផ្ទាល់ជាមួយអ្នកស្នើសុំ ឬតាមរយៈការប្រកាសផ្សព្វផ្សាយតាមមធ្យោបាយនានាដូចជា ឧគ្ឃោសនស័ព្ទ ឬវិទ្យុ និងឬតាមមធ្យោបាយសមស្របផ្សេងៗទៀត។
  - ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ៖ អាចធ្វើឡើងតាមរយៈលិខិត ឬសារព័ត៌មាន សម្រាប់ឆ្លើយតបចំពោះបុគ្គល ឬក្រុមអ្នកស្នើសុំ។

- ការដោះស្រាយ ឬការចាត់វិធានការ ឬការអនុវត្តសកម្មភាពណាមួយ ដែលចូលរួមចំណែកក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ជាការប្រសើរ ការឆ្លើយតបតាមរយៈការដោះស្រាយត្រូវធ្វើឡើងមិនគួរលើសរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលបានបញ្ហា តម្រូវការ និងឬមតិយោបល់ពីប្រជាពលរដ្ឋ។ ឧទាហរណ៍៖ ប្រជាពលរដ្ឋស្នើសុំឲក្រុមប្រឹក្សាស្រុកជួយដោះស្រាយបញ្ហាគ្មានអនាម័យនៅក្នុងផ្សារក្នុងទីរួមស្រុករបស់ខ្លួន។ បន្ទាប់ពីទទួលបានការស្នើសុំនេះ ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងសម្រេចអំពីដំណោះស្រាយបញ្ហានេះ និងណែនាំឲអភិបាល ចាត់ចែងអនុវត្តសេចក្តីសម្រេចនេះប្រកបដោយប្រសិទ្ធភាព។ ចំណាត់ការរបស់ក្រុមប្រឹក្សានេះ គឺជាការអនុវត្តគណនេយ្យភាព ចំពោះប្រជាពលរដ្ឋតាមរយៈការដោះស្រាយនូវបញ្ហារបស់ប្រជាពលរដ្ឋ។

បទពិសោធន៍ ៖ អភិបាលរងខណ្ឌ០១រូបបានមានប្រសាសន៍ថា ការតវ៉ារបស់ប្រជាពលរដ្ឋមិនមែនជារឿងអាក្រក់ទាំងអស់នោះទេ។ ជាការពិត នៅពេលប្រជាពលរដ្ឋមិនពេញចិត្តនឹងអ្វីដែលរដ្ឋបាលខណ្ឌបានធ្វើនោះពួកគាត់នឹងធ្វើការតវ៉ា។ ដូច្នេះរដ្ឋបាលខណ្ឌ ចាំបាច់ត្រូវពិនិត្យមើលលើបញ្ហាដែលប្រជាពលរដ្ឋបានលើកឡើងដោយត្រូវសិក្សា ស្រាវជ្រាវឲបានច្បាស់លាស់ ហើយត្រូវឆ្លើយតបទៅប្រជាពលរដ្ឋវិញឲបានលឿនតាមដែលអាចធ្វើបាន។ រាល់ការឆ្លើយតបត្រូវតែមានហេតុផលត្រឹមត្រូវ សមហេតុផល និង អាចទទួលយកបានពីសំណាក់ប្រជាពលរដ្ឋដែលបានមកតវ៉ានោះ។

រូបភាពទី៨៖ ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់និងក្រុង




| | តួនាទី និងការទទួលខុសត្រូវរបស់សង្កាត់ | តួនាទី និងការទទួលខុសត្រូវរបស់ក្រុង | តម្លាភាពសេវាសាធារណៈ | ការទទួលខុសត្រូវរបស់អ្នកសេវាសាធារណៈ | សេវាការិយាល័យច្រកចេញចូលតែមួយ | សេវាការិយាល័យប្រជាពលរដ្ឋ | តួនាទី និងការទទួលខុសត្រូវរបស់គកនក/គកសក | យន្តការច្រកចេញចូលតែមួយរបស់សង្កាត់ | ការកំណត់អត្តសញ្ញាណបញ្ហាប្រឈមនៃសេវាសាធារណៈ | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|---|---|
| យល់ដឹងល្អណាស់ | 0.0% | 1.2% | 0.6% | 0.0% | 0.0% | 1.7% | 0.6% | 0.6% | 0.0% | 0.5% |
| យល់ដឹងបានល្អ | 1.7% | 2.3% | 0.6% | 1.7% | 2.3% | 2.9% | 1.1% | 1.2% | 3.5% | 1.9% |
| យល់ដឹងជាបង្គួរ | 15.9% | 8.7% | 9.1% | 2.3% | 10.8% | 4.0% | 2.3% | 3.5% | 3.5% | 6.7% |
| យល់ដឹងតិចតួច | 34.7% | 9.2% | 16.0% | 13.6% | 24.4% | 4.6% | 6.9% | 16.8% | 17.0% | 15.9% |
| មិនយល់ដឹង | 47.7% | 78.6% | 73.7% | 82.4% | 62.5% | 86.8% | 89.1% | 78.0% | 76.0% | 75.0% |

រូបភាពនេះ បង្ហាញពីការវាស់វែងលើការយល់ដឹងរបស់ប្រជពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់និងក្រុង។ អថេរសម្រាប់វាស់វែងមានដូចជា តួនាទីនិងការទទួលខុសត្រូវរបស់សង្កាត់ តួនាទីនិងការទទួលខុសត្រូវរបស់ក្រុង តម្លាភាពសេវាសាធារណៈ ការទទួលខុសត្រូវរបស់អ្នកសេវាសាធារណៈ សេវាការិយាល័យច្រកចេញចូលតែមួយ សេវាការិយាល័យប្រជាពលរដ្ឋ តួនាទី និងការទទួលខុសត្រូវរបស់គកសក

យន្តការច្រកចេញចូលតែមួយរបស់សង្កាត់ និងការកំណត់អត្តសញ្ញាណបញ្ហាប្រឈមនៃសេវាសាធារណៈ។ ជាលទ្ធផលមធ្យមភាគ វាបង្ហាញឲ្យឃើញថាម មានអ្នកមិនយល់សោះ មាន៧៥% អ្នកយល់តិចតួច មាន១៥.៩% អ្នកយល់ដឹងបង្គួរ មាន៦.៧% អ្នកយល់ដឹងបានល្អ មាន១.៩% និងអ្នកយល់ដឹងល្អណាស់ មាន០.៥%។

រូបភាពទី៩៖ ការដឹង និងស្គាល់របស់ប្រជាពលរដ្ឋអំពីការិយាល័យសេវាសាធារណៈ




រូបភាពនេះ បង្ហាញពីការវាស់វែងលើការដឹង និងស្គាល់របស់យុវជន និងប្រជាសហគមន៍អំពីការិយាល័យសេវាសាធារណៈមានដូចជា ស្គាល់អំពីសង្កាត់ ស្គាល់អំពីសាលាក្រុង ស្គាល់អំពីការិយាល័យច្រកចេញចូលតែមួយ ស្គាល់អំពីការិយាល័យពលរដ្ឋ ដឹងអំពីសេវាកម្មសង្កាត់ ដឹងអំពីសេវាកម្មសាលាក្រុង ដឹងអំពីការិយាល័យច្រកចេញចូលតែមួយ ដឹងអំពីការិយាល័យពលរដ្ឋ ។ គិតជាមធ្យមលើអថេរទាំង៨ អ្នកមិលស្គាល់ ឬមិនដឹង មានចំនួន៦១.៩% និងអ្នកដឹង ឬស្គាល់មានចំនួន៣៨.៩១% ។

រូបភាពទី១០៖ ការចូលរួមប្រជាពលរដ្ឋក្នុងការផ្តល់សេវាកម្មសាធារណៈរបស់សង្កាត់និងក្រុង




រូបភាពនេះ បង្ហាញពីការវាស់វែងលើការចូលរួមរបស់យុវជននិងប្រជាពលរដ្ឋក្នុងការផ្តល់សេវាកម្មសាធារណៈរបស់សង្កាត់និងក្រុង។ អថេរដែលត្រូវវាស់វែងមានដូចជា ការតាមដានល់ការផ្តល់សេវាសាធារណៈ ការចូលរួមក្នុងការប្រជុំពិគ្រោះយោបល់របស់សង្កាត់ ការចូលរួមក្នុងការប្រជុំពិគ្រោះយោបល់របស់ក្រុង ការចូលរួមក្នុងការប្រជុំប្រចាំខែរបស់សង្កាត់ ការចូលរួមក្នុងការប្រជុំប្រចាំខែរបស់ក្រុង ការលើកជាបញ្ហារ និងសំណូមពរដល់សង្កាត់/ក្រុង ការចោទសួរជាសំណួរទៅសង្កាត់/ក្រុង ជួបបញ្ហាប្រឈមក្នុងខណៈពេលប្រើសេវាសង្កាត់/ក្រុង និងជួបបញ្ហាប្រឈមក្នុងខណៈពេលប្រើសេវាច្រកតែមួយ។ នៅក្នុងបាធាត វាបង្ហាញថា មានយុវជន និងប្រជាពលរដ្ឋប្រមាណ៩១.៩២% មិនធ្លាប់ ឬមិនបានចូលរួម ឬពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មរបស់ក្រុមប្រឹក្សាសង្កាត់ និងក្រុង គឺមានតែ៨.៨%បានចូលរួម និងពាក់ព័ន្ធក្នុងដំណើរការផ្តល់សេវាកម្មរបស់ក្រុមប្រឹក្សាសង្កាត់និងក្រុងកំពង់ចាម។

ជាសរុប លទ្ធផលពីការស្រាវជ្រាវដែលអនុវត្តដោយយុវជនវ័យក្មេងបានបង្ហាញឲ្យឃើញថា ការយល់ដឹងរបស់យុវជន និងប្រជាសហគមន៍អំពីអភិបាលកិច្ចមូលដ្ឋាន និងសេវាកម្មសាធារណៈ គិតជាមធ្យមភាគ អ្នកមិនយល់ដឹងសោះ មាន៧២% អ្នកយល់ដឹងតិចតួច មាន១៧.៧% អ្នកយល់ដឹងជាបង្គួរ មាន៧.៤% អ្នកយល់ដឹងល្អ មាន ២.៥% និង យល់ដឹងច្បាស់ មានចំនួន០.៤% ។

**តារាងលទ្ធផលទី១៖** ការយល់ដឹងរបស់យុវជន និងប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

| លរ | អថេរ | មិនយល់ដឹង | យល់ដឹងតិចតួច | យល់ដឹងជាបង្គួរ | យល់ដឹងបានល្អ | យល់ដឹងល្អណាស់ |
|---|---|---|---|---|---|---|
| 1 | និយមន័យនៃអភិបាលកិច្ចល្អ | 75.4% | 14.5% | 7.9% | 2.2% | 0.0% |
| 2 | គោលការណ៍នៃអភិបាលកិច្ចល្អ | 78.8% | 11.2% | 10.0% | 0.0% | 0.0% |
| 3 | កត្តាដែលនាំឲ្យមានសង្គមល្អ | 46.1% | 36.5% | 13.5% | 3.9% | 0.0% |
| 4 | តួនាទី និងការទទួលខុសត្រូវរបស់សង្កាត់ | 47.7% | 34.7% | 15.9% | 1.7% | 0.0% |
| 5 | តួនាទី និងការទទួលខុសត្រូវរបស់ក្រុង | 78.6% | 9.2% | 8.7% | 2.3% | 1.2% |
| 6 | ការកំណត់អត្តសញ្ញាណនៃការចូលរួម | 72.0% | 18.3% | 5.7% | 4.0% | 0.0% |
| 7 | ការកំណត់អត្តសញ្ញាណពលរដ្ឋសកម្ម | 43.7% | 39.7% | 10.9% | 4.0% | 1.7% |
| 8 | ការចូលរួមធ្វើផែនការអភិវឌ្ឍន៍នានា | 73.0% | 16.7% | 6.3% | 4.0% | 0.0% |
| 9 | ការធ្វើផែនការអភិវឌ្ឍន៍សង្កាត់ | 68.4% | 19.0% | 6.9% | 5.7% | 0.0% |
| 10 | ការធ្វើថវិកាអភិវឌ្ឍន៍សង្កាត់ | 69.8% | 16.5% | 9.7% | 3.4% | 0.6% |
| 11 | ការធ្វើផែនការអភិវឌ្ឍន៍ក្រុង | 80.0% | 10.9% | 6.9% | 2.2% | 0.0% |
| 12 | ការធ្វើថវិកាអភិវឌ្ឍន៍ក្រុង | 86.1% | 9.2% | 3.5% | 0.6% | 0.6% |
| 13 | គម្លាភាពសេវាសាធារណៈ | 73.7% | 16.0% | 9.1% | 0.6% | 0.6% |
| 14 | ការទទួលខុសត្រូវរបស់អ្នកសេវាសាធារណៈ | 82.4% | 13.6% | 2.3% | 1.7% | 0.0% |
| 14 | សេវាការិយាល័យច្រកចេញចូលតែមួយ | 62.5% | 24.4% | 10.8% | 2.3% | 0.0% |
| 15 | សេវាការិយាល័យប្រជាពលរដ្ឋ | 86.8% | 4.6% | 4.0% | 2.9% | 1.7% |
| 16 | តួនាទី និងការទទួលខុសត្រូវរបស់គកនក/គកសក | 89.1% | 6.9% | 2.3% | 1.1% | 0.6% |
| 17 | យន្តការច្រកចេញចូលតែមួយរបស់សង្កាត់ | 78.0% | 16.8% | 3.5% | 1.2% | 0.6% |
| 18 | ការកំណត់អត្តសញ្ញាណបញ្ហាប្រឈមនៃសេវាសាធារណៈ | 76.0% | 17.0% | 3.5% | 3.5% | 0.0% |
| **ជាមធ្យមភាគ** | | **72.0%** | **17.7%** | **7.4%** | **2.5%** | **0.4%** |

## ៥.៤ការយល់ដឹងរបស់យុវជន និងប្រជាសហគមន៍អំពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន

ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាសកម្មភាពជាបុគ្គល ឬជាក្រុមដែលកើតឡើងក្នុងដំណើរការនានាដែលបុគ្គល ឬក្រុមអ្នកពាក់ព័ន្ធទាំងនោះបានរួមចំណែក ឬមានឥទ្ធិពលក្នុងដំណើរការកំណត់អាទិភាពលើបញ្ហាអ្វីមួយ ដូចជាការរៀបចំគោលនយោបាយ ការវិភាជន៍ និងការប្រើប្រាស់ធនធានក្នុងការធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ ។

ការចូលរួមរបស់ប្រជាពលរដ្ឋមិនត្រឹមតែជាការស្តាប់នូវយោបល់របស់ប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធប៉ុណ្ណោះទេ តែទទួលខុសត្រូវទៅវិញទៅមក។ ក្រុមប្រឹក្សាមានកត្តព្វកិច្ចពន្យល់ និងបកស្រាយនូវសេចក្តីសម្រេចនានារបស់ខ្លួនជូនដល់ប្រជាពលរដ្ឋ សហគមន៍និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនវិញ។ ក្រុមប្រឹក្សាត្រូវតែជួបប្រាស្រ័យទាក់ទងជាប្រចាំជាមួយប្រជាពលរដ្ឋ ក្រុមអ្នកទទួលផល អង្គការសង្គមស៊ីវិល និងផ្នែកឯកជនផងដែរ តាមរយៈការជួបប្រជុំក្នុងកិច្ចប្រជាសាធារណៈ វេទិការផ្សព្វផ្សាយ ពិគ្រោះយោបល់ និងវេទិការផ្សេង។

ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាកត្តាគន្លឹះនៃអភិបាលកិច្ចល្អ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែបង្កើននូវឱកាសប្រកបដោយការលើកទឹកចិត្ត និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋអាចធ្វើសកម្មភាពស្របទៅតាមផលប្រយោជន៍របស់ខ្លួន និងផលប្រយោជន៍រួមដោយគ្មានការរឹតត្បិត ឬភ័យខ្លាចពីការរើសអើងផ្សេងៗ។

សេវាសាធារណៈ គឺជាសេវាដែលរដ្ឋផ្តល់ជូនប្រជាជនតាមរយៈអង្គភាពសាធារណៈ និងគ្រឹះស្ថានសាធារណៈ សំដៅបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ គ្រប់ស្រទាប់វណ្ណៈ ដោយពុំមានការរើសអើង។ ដើម្បីឲ្យដំណើរការនៃការផ្តល់សេវាសាធារណៈបានល្អ លុះត្រាតែ សមាសភាពបីមានភាពស៊ីសង្វាក់គ្នា និងទំនាក់ទំនងល្អនឹងគ្នា ហើយសមាសភាពទាំងនោះ រួមមាន អ្នកប្រើប្រាស់សេវា អ្នកផ្តល់សេវា និងអ្នកតាក់តែងគោលនយោបាយ។

រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈយ៉ាងមោះមុតក្នុងការជំរុញការអនុវត្តការងារកំណែទម្រង់គ្រប់ផ្នែក គ្រប់វិស័យ ឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅក្នុងគោលបំណងធ្វើឱ្យប្រទេសកម្ពុជាមានសុខដុមនីយកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋ។ ផ្អែកលើស្មារតីនេះ ការលើកកម្ពស់អភិបាលកិច្ចល្អ ក្នុងរដ្ឋបាលសាធារណៈ គឺជាកម្លាំងចលករដ៏ចាំបាច់ដែលរាជរដ្ឋា ភិបាលគ្រប់ជាន់ថ្នា ក់ត្រូវ យកចិត្តទុកដាក់ជាអាទិភាពបំផុត។ អភិបាលកិច្ចល្អត្រូវបានរាជរដ្ឋា ភិបាលកំណត់ថាជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក្នុងការជំរុញការអនុវត្តគោលនយោបាយវិ មជ្ឈការ និងវិ សហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់តាមវិ ស័យផ្សេងៗទៀត របស់រាជរដ្ឋា ភិបាល។

### ៥.៥ ការយល់ដឹងរបស់អាជ្ញាធរ និងអ្នកពាក់ព័ន្ធអំពីអភិបាលកិច្ចមូលដ្ឋាន

**គណនេយ្យភាពសង្គម** គឺជាផ្នែកមួយនៃការពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យនៅកម្ពុជា គឺជាឧបករណ៍ដ៏មានសារៈសំខាន់ ក្នុងការចូលរួមចំណែកដល់ការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ដោយឈរលើគោលការណ៍ជាមូលដ្ឋានចំនួនបី គឺ (១) ការទទួលបានព័ត៌មាន (២) ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និង(៣) ការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋក្នុងដំណើរការពិភាក្សាធ្វើឲ្យមាន ភាព ប្រសើរឡើង។ និយាយឱ្យសាមញ្ញទៅ **គណនេយ្យសង្គម** គឺជាមធ្យោបាយទាំងឡាយណា ដែលអនុវត្តដោយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ដើម្បីជួយដល់រដ្ឋាភិបាល ឬអ្នកផ្តល់សេវាកម្មសាធារណៈមានគណនេយ្យភាព (ការ ទទួលខុសត្រូវខ្ពស់) តម្លាភាព និងឆ្លើយតបតាមតម្រូវការរបស់សហគមន៍។

ការអនុវត្តវិមជ្ឈការនៅថ្នាក់ឃុំសង្កាត់ រាជរដ្ឋាភិបាល បានបន្តការប្តេជ្ញាចិត្តក្នុងការអនុវត្តដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលក្នុងដំណើរការនោះ រាជរដ្ឋាភិបាល បានសម្រេចនូវ លទ្ធផលជាផ្លែផ្កាជាច្រើន ដូចជា ការរៀបចំ ការអនុម័ត និងដាក់ឱ្យអនុវត្តនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី-ខេត្តក្រុង-ស្រុក-ខណ្ឌក្នុងឆ្នាំ២០០៨ និងការបោះឆ្នោតជ្រើសរើសក្រុម

ប្រឹក្សានៅកម្រិតរដ្ឋបាល ទាំង២ ថ្នាក់អណត្តិទី១នៃរដ្ឋបាលថ្នាក់ក្រោមជាតិ នាខែឧសភា ឆ្នាំ២០០៩ និងការបោះឆ្នោតអណត្តិទី២ នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤។ ទាំងនេះ បានបង្ហាញឱ្យឃើញនូវកំណែទម្រង់ដ៏មានសារៈសំខាន់មួយ នៃរចនាសម្ព័ន្ធគ្រប់គ្រងនៃរាជរដ្ឋាភិបាលកម្ពុជា។ គោលដៅសំខាន់នៃកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺ "ការលើកកម្ពស់សុខមាលភាព ( ទាំងសម្លេង ទាំងសិទ្ធិ និងជីវភាពរស់នៅ ) របស់ប្រជាពលរដ្ឋ ការលើកកម្ពស់សមភាពរវាងប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងការធានានូវយុត្តិធម៌ក្នុងការទទួលបានសេវាសាធារណៈ"។

ការកែលម្អ និងការផ្លាស់ប្តូរឥរិយាបទនៃភាពជាតំណាង ព្រមទាំងការផ្តល់ឱកាសចូលរួមជាសម្លេង ជាសិទ្ធិដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កាន់តែទូលំទូលាយ ក្នុងការប្រាស្រ័យទាក់ទងជាមួយតំណាងរបស់ខ្លួន និងការជម្រុញឱ្យមានគណនេយ្យភាពកាន់តែខ្លាំងឡើង របស់ក្រុមប្រឹក្សានិងមន្ត្រីនានាចំពោះប្រជាពលរដ្ឋនឹងបង្កើននូវមូលធនសង្គម និងការផ្សារភ្ជាប់នៅសហគមន៍ គឺជាធាតុចូលដ៏មានសារសំខាន់ និងមានប្រសិទ្ធភាពក្នុងដំណើរការការអភិវឌ្ឍន៍សង្គមជាតិឱ្យបានរុងរឿងគ្រប់វិស័យទៅអនាគត។

នៅឆ្នាំ២០១៣ កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានឈានចូលក្នុងដំណាក់កាលកាន់តែស៊ីជម្រៅថែមទៀត។ រចនាសម្ព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញស្របតាមគោលការណ៍ដែលបានចែងក្នុងច្បាប់រៀបចំអង្គការ កម្មវិធីរយៈពេល១០ឆ្នាំ និងផែនការអនុវត្តន៍ រយៈពេល៣ឆ្នាំដំបូងនៃកម្មវិធីជាតិនេះ។ ការអនុវត្តន៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់ ក៏បានបង្ហាញនូវលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន មានសិទ្ធិចូលរួមស្តាប់ និយាយ និងធ្វើការបញ្ចេញមតិយោបល់សម្រាប់ការពង្រឹងអភិបាលកិច្ចល្អ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិតជាបានរួមចំណែកដល់ការពង្រឹង លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ប្រជាជន ការពង្រឹងភាពជាអ្នកដឹកនាំ នៅមូលដ្ឋាន ទាំងស្ត្រី ទាំងបុរស និងក៏បានធ្វើឱ្យមានការកែលម្អនូវការផ្តល់សេវាសាធារណៈនៅមូលដ្ឋានផងដែរ។

**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ (២០១៣-២០១៨) បានដាក់ចេញនូវ គោលដៅយុទ្ធសាស្ត្រ ៤ និង វិស័យអាទិភាព៤ ដើម្បីឆ្លុះបញ្ចាំងពីប្តេជ្ញាចិត្តក្នុងការអនុវត្ត រយៈពេល៥ឆ្នាំទៅមុខ។ គោលដៅទី៤ គឺបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។**

យោងតាមការចាំបាច់នេះ កម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ត្រូវបានរៀបចំបង្កើតឡើង និងបានអនុម័តនៅអំឡុងខែឧសភា ឆ្នាំ ២០១០ ដែលផ្តល់ឱកាសឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់ បានសម្របសម្រួល និងអនុវត្តដោយសន្សឹមៗ ប្រកប ដោយភាពជឿជាក់

តាមរយៈការរៀបចំជាយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធទៅនឹង រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ ផែនការ និងធនធានមនុស្ស ព្រមទាំងប្រព័ន្ធសម្រាប់ផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិ១០ឆ្នាំនេះ ដឹកនាំអនុវត្តដោយគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។ គ.ជ.អ.ប ដែលបានបង្កើតឡើង គឺដើម្បីជួយរាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រម ទាំងសម្របសម្រួលការអនុវត្ត និងការត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប តេយ្យនៅថ្នាក់ក្រោមជាតិ។ គ.ជ.អ.ប បាននិងកំពុងដំណើរការនិងធ្វើការជាមួយគ្រប់ស្ថាប័នរបស់រាជរដ្ឋា ភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្រេចឱ្យបាននូវគោលបំណងរួមរបស់រាជរដ្ឋាភិបាល ក្នុងការលើកស្ទួយ និងរក្សាបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ឧបករណ៍សម្រាប់អនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំនេះ គឺផែនការអនុវត្តរយៈពេល៣ឆ្នាំ ដែលហៅ កាត់ថា ផអ៣ (២០១១-២០១៣) ដែលបានរៀបចំឡើងនៅឆ្នាំ២០១១ ហើយដោយសារនៅមានការងារ សេសសល់ជាច្រើននៅមិនទាន់បានបញ្ចប់នៅចុងឆ្នាំ២០១៣ ហេតុនេះ ទើបមានការព្រមព្រៀងឱ្យបន្ត អនុវត្ត ផអ៣មួយឆ្នាំបន្ថែមទៀតនោះគឺ **ផអ៣ឆ្នាំ ២០១៤**។ បច្ចុប្បន្ន **ផអ៣ ដំណាក់កាលទី២** ក៏បាននឹងកំពុងរៀបចំតាក់តែងឡើង ដែលនឹងយកទៅពិគ្រោះយោបល់ ក្នុងពេលឆាប់ៗខាងមុខនេះ។
គោលបំណងដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាល សម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺដើម្បី៖

- ❖ បង្កើតវប្បធម៌ប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាពលរដ្ឋ និងប្រកបដោយការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ
- ❖ កែលម្អការផ្តល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ
- ❖ នាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច
- ❖ ចូលរួមកាត់បន្ថយភាពក្រីក្រ។

ការតាំងចិត្តរបស់រាជរដ្ឋាភិបាលចំពោះការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក៏មានចែងនៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយបានកំណត់យ៉ាងច្បាស់អំពីការតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈ(១)ភាពជាតំណាងសាធារណៈ (២) ស្វ័យភាពរបស់មូលដ្ឋាន (៣)ការពិគ្រោះយោបល់និងការចូលរួម(៤)ការឆ្លើយតបនិងគណនេយ្យភាព (៥)ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦)ការលើកស្ទួយសមធម៌ (៧)តម្លាភាពនិងសុចរិតភាព និង(៨)វិធានការប្រឆាំងអំពើពុករលួយ និងការ រំលោភអំណាច។

ពាក់ព័ន្ធចំពោះគណនេយ្យភាពវិញ ឯកសារកម្មវិធីជាតិ១០ឆ្នាំ បានកំណត់ឱ្យមានខ្សែគណនេយ្យភាពចំនួនបួនដូចខាងក្រោម:

1. **គណនេយ្យភាពផ្ទៃក្នុង៖** សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
2. **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ៖** សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។
3. **គណនេយ្យភាពអន្តររដ្ឋបាល៖** សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
4. **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ៖** សំដៅទៅលើខ្សែគណនេយ្យភាពផ្នែកនយោបាយ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**យោងតាមចំនុចទី៤នៃខ្សែគណនេយ្យភាព** ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមមួយ ត្រូវបានរៀបចំឡើង និងបានអនុម័តនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។ យោងតាមឯកសារយុទ្ធសាស្ត្រគណនេយ្យភាពសង្គមដែលបានអនុម័តរួចនេះ ផែនការអនុវត្ត៣ឆ្នាំ ក៏បានរៀបចំឡើងដែរ ដើម្បីប្រែក្លាយយុទ្ធសាស្ត្រ នោះឱ្យទៅជាសកម្មភាពជាក់ស្តែងដើម្បីរួមចំណែកពង្រឹងទំនាក់ទំនង ភាពជាដៃគូ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋ លើកកម្ពស់សិទ្ធអំណាចរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសំដៅអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព។ តែអ្វីដែលគួរឲកត់សម្គាល់នោះ គឺស្ត្រីត្រូវបានយកចិត្តទុកដាក់ជាពិសេស គ្រប់ផ្នែកទាំងអស់នៃកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ ស្ត្រីត្រូវបានលើកទឹកចិត្តទាំងផ្នែកស្មារតី សម្ភារៈ និងថវិកា នឹងមានផ្តល់ការបណ្តុះបណ្តាពង្រឹងសមត្ថភាពដើម្បីអោយចូលរួមក្នុងសកម្មភាពរបស់ក្រុមប្រឹក្សា ឬ គណៈអភិបាល។

**ហេតុអ្វីបានជាគណនេយ្យភាពសង្គមឆ្លើយតបចំពោះយេនឌ័រជាធាតុដ៏សំខាន់?**

គណនេយ្យភាពសង្គមឆ្លើយតបទៅនឹងតម្រូវការនិងជាអាទិភាពរបស់បុរសនិងស្ត្រី ដែលឆ្លើយតបទៅនឹងក្តីកង្វល់ និងបញ្ហាដែលប្រជាពលរដ្ឋបានលើកឡើង។ ការបញ្ចូលបញ្ហារបស់ស្ត្រីទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សា គឺជាការផ្តល់ឱកាសឲស្ត្រីបានលើកនូវក្តីកង្វល់ និងតម្រូវការជាអាទិភាព របស់ខ្លួនទៅកាន់ក្រុមប្រឹក្សាឲជួយស្វែងដំណោះស្រាយ ហើយអ្វីដែលពិសេសនោះ គឺស្ត្រីមានឱកាស មានសិទ្ធិក្នុងការបញ្ចេញមតិជាសាធារៈ។ យើងបានដឹងច្រើនមកហើយថា ច្បាប់ឬគោលនយោបាយ បានបង្កើតមកដើម្បីគាំទ្រ ឬ គាំពារចំពោះស្ត្រី ប៉ុន្តែការអនុវត្តជាក់ស្តែងវិញមិនត្រូវបានប្រើប្រាស់ប្រកបដោយតម្លាភាពនោះឡើយ ហេតុនេះគណនេយ្យភាពបានជួយសម្រួលដល់ស្ត្រីក្នុងការបង្កើនឱកាសឲស្ត្រីមានវត្តមាន មានន័យថា ស្ត្រីហ៊ានចូលរួម ហើយហ៊ាននិយាយហ៊ានលើកបញ្ហា និងមានការបញ្ចេញមតិយោបល់ក្នុងសកម្មភាពជាមួយក្រុមប្រឹក្សា គណៈភិបាលក្រុង ស្រុកជាដើម។

## ហេតុអ្វីបានជាស្ត្រីត្រូវចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សា ?



ស្ត្រីបានលើកពីបញ្ហា និងតម្រូវការអាទិភាពឲក្រុមប្រឹក្សាដោះស្រាយ និងបញ្ចូលក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ដឹងពីការសម្រេចចិត្ត ចំណូលចំណាយ និងទទួលបានព័ត៌មានថ្មីៗ ទាក់ទងនិងការអភិវឌ្ឍ ការរៀនសូត្រ ផ្សេងៗ ទទួលបានការឆ្លើយតប និងផ្តល់សេវាត្រឹមត្រូវពីក្រុមប្រឹក្សា ចូលរួមផ្តល់យោបល់លើការអនុវត្តការងារ របស់ក្រុមប្រឹក្សា បានដឹងពីតួនាទី និងសកម្មភាពរបស់ក្រុមប្រឹក្សា ស្គាល់និងមានទំនាក់ទំនងល្អជាមួយក្រុមប្រឹក្សា ផ្តល់យោបល់លើផែនការ និងការប្រើប្រាស់ថវិកា។ ការចូលរួមរបស់ស្ត្រីធ្វើអោយមានឥទ្ធិពលក្នុងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា និងធ្វើអោយស្ត្រីហ៊ានចូលរួម ហ៊ាននិយាយ លើកបញ្ហា លើកមតិយោបល់កែលម្អរកិច្ចការងារក្រុមប្រឹក្សាកើនឡើងច្រើនដូចបុរស និងចុងក្រោយគឺក្រុមប្រឹក្សាធ្វើការឆ្លើយតបនិងដោះស្រាយបញ្ហាដែលបានលើកជូនស្ត្រី ដូចបុរសដែរ។

## តើស្ត្រីចូលរួមសកម្មភាពជាមួយក្រុមក្រុមប្រឹក្សា ដោយរបៀបណា ?



គណៈអភិបាលក្រុង ស្រុកដែលមានចំនួយ ៣ ទៅ ៥រូប (អភិបាលម្នាក់ និងអភិបាលរងមួយចំនួន)និងមន្ត្រីជំនាញជុំវិញការិយាល័យ បានបង្កើនឱកាសនិងបើកចំហរ ពិភាក្សានិងពីគ្រោះយោបល់ជាមួយប្រជាពលរដ្ឋតាមរយះ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ

សង្កាត់ សកម្មភាពចុះពិគ្រោះយោបល់នៅមូលដ្ឋាន ម៉ោងជួបប្រជាពលរដ្ឋ កិច្ចប្រជុំដំណើរការកសាងផែនការវិនិយោគឃុំ សង្កាត់ ការកសាងផែនការថវិកាក្រុង ស្រុក ឃុំ សង្កាត់ ប្រអប់សំបុត្រគណនេយ្យភាពនៅភូមិ ឃុំសង្កាត់ ក្រុងស្រុក។ ទាំងអស់នេះគឺជាបើកឱកាសអោយប្រជាពលរដ្ឋ ជាពិសេសស្ត្រីដែលត្រូវបានចាត់ទុកជាជនងាយរងគ្រោះ បានបញ្ចេញមតិ និងពិភាក្សាដេញដោលក្នុងគោលបំណង ទទួលដឹងសិទ្ធិ តួនាទី សកម្មភាព និងទទួលបានការឆ្លើយតប និងសេវាត្រឹមត្រូវពីក្រុមប្រឹក្សា។

ការយល់ដឹងលើយេនឌ័រនឹងត្រូវបានសរសេរផ្តោតទៅលើលទ្ធផលនៃការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងសកម្មភាពអភិវឌ្ឍន៍ និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា តាមរយៈដំណើរ និងសកម្មភាពបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី។ លទ្ធផលនៃការលើកកម្ពស់យេនឌ័រ អាចនឹងត្រូវប្រមូលទៅតាមកម្រិតលទ្ធផលជាបន្តបន្ទាប់ដូចខាងក្រោម៖

- **កម្រិត ១៖** ការកើនឡើងនូវសមត្ថភាព និងការយល់ដឹង
- **កម្រិត ២៖** ការអនុវត្តការយល់ដឹងដើម្បីលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- **កម្រិត ៣៖** ភាពប្រសើរឡើងនូវការចូលរួមរបស់ស្ត្រី និងបុរស និងការកើនឡើងនូវទំនុកចិត្តរបស់ ស្ត្រី បុរស ។ ផ្នែកអ្នកផ្តល់សេវាយកចិត្តទុកដាក់ ចាត់វិធានការ ដោះស្រាយ និងឆ្លើយតបបញ្ហាស្ត្រីដូចបុរស។
- **កម្រិត៤៖** ប្រសិទ្ធភាពនៃការអនុវត្តការលើកកម្ពស់យេនឌ័រ។ ស្ត្រី បុរសបានទទួលលទ្ធផលដូចគ្នា និងមានសមភាពយេនឌ័រ។

នៅក្នុងកម្រិតទាំង៤ កម្រិតដែលទាបជាងគេគឺកម្រិត១ (លទ្ធផលសម្រេចបាន រយៈពេលខ្លី) និង កម្រិតដែលខ្ពស់ជាងគេ គឺកម្រិតទី៤ (លទ្ធផលសម្រេចបានបែបប្រសិទ្ធិភាពនិងមានការផ្លាស់ប្តូរ រយៈពេលវែង)

លើសអំពីកម្រិតនៃលទ្ធផលដែលបានរៀបរាប់ខាងលើ របាយការណ៍ត្រូវរំលេចឲយើញនូវសកម្មភាព និងលទ្ធផលជាក់លាក់មួយចំនួនដូចខាងក្រោម៖

- លទ្ធផលដែលស្ត្រី បុរស ក្មេងស្រី ក្មេងប្រុស ជនជាតិដើមភាគតិច អ្នកក្រីក្រខ្លាំង ចាស់ជរា អ្នកមានជំងឺ ទទួលបានខុសៗគ្នាពីគ្រប់កម្រិតនៃការអនុវត្តន៍
- វគ្គបណ្តុះបណ្តាលបានទទួលស្គាល់នូវតម្រូវការ និងតួនាទីខុសគ្នារបស់ស្ត្រី បុរសឲចូលរួមនៅក្នុងសកម្មភាពក្រុមប្រឹក្សា និងសកម្មភាពនៃការអនុវត្តន៍
- ការប្រើវិធីសាស្ត្រចំរុះដើម្បីភ្ជាប់ទំនាក់ទំនង និងបង្កើនសមត្ថភាព និងទំនុកចិត្តដល់ស្ត្រី ក្រុមជនងាយរងគ្រោះឲបានចូលរួមនៅក្នុងសកម្មភាពក្រុមប្រឹក្សា
- សកម្មភាពដែលធានាឲមានការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សាទៅកាន់សហគមន៍ដោយស្មើភាព

- សកម្មភាពបង្ហាត់បង្ហាញក្រុមប្រឹក្សាឲទទួលស្គាល់នូវភាពខុសគ្នារបស់ស្ត្រី បុរស យេនឌ័រ និងប្រភេទសមភាពជនទៃផ្សេងទៀតនៅក្នុងអភិបាលកិច្ចមូលដ្ឋាន
- ការគាំទ្ររបស់គម្រោងដល់ក្រុមប្រឹក្សាឲអនុវត្តការផ្តល់ឱកាស និងសុវត្ថិភាពសម្រាប់ស្ត្រី និងក្រុមជនងាយរងគ្រោះឲទទួលបានឱកាស និងទំនុកចិត្ត ចូលរួមធ្វើការសម្រេចចិត្ត។*(ឧ. បង្ហាត់បង្ហាញក្រុមប្រឹក្សាឲទុកពេលមានរបៀបវារៈសម្រាប់ស្ត្រី លើកបញ្ហា តម្រូវការ លើកទឹកចិត្តក្រុមប្រឹក្សាចុះពិគ្រោះយោបល់ជាមួយក្រុមស្ត្រី និងស្តាប់តម្រូវការជាអាទិភាពរបស់ស្ត្រី។)*
- សកម្មភាពភ្ជាប់ទំនាក់ទំនង ឬកិច្ចសហប្រត្តិបត្តិការជាមួយ គ.ក.ស.ក[២] និង គ.ក.ន.ក[៣] ក្នុងការលើកកម្ពស់ការផ្តល់ឱកាស់ដល់ស្ត្រី និងក្រុមជនងាយរងគ្រោះ មានឥទ្ធិពលលើការសម្រេចចិត្តរបស់ក្រុមប្រឹក្សា
- សកម្មភាពដែលបានអនុវត្តជាមួយអ្នកដឹកនាំចាស់ព្រឹទ្ធាចារ្យ ដូចជាតាតា ឬបុរសគម្រូ ស្ត្រីគម្រូនៅក្នុងការលើកទឹកចិត្តស្ត្រីបានចូលរួម និងបានទទួលប្រយោជន៍ពីគម្រោង
- សហគមន៍មូលដ្ឋាន យុវវ័យ ស្រី ប្រុស ចូលរួមក្នុងកិច្ចការអភិបាលកិច្ចមូលដ្ឋាន *(សហគមន៍មូលដ្ឋាន យុវវ័យធ្វើការផ្សព្វផ្សាយចំណេះដឹងបន្ត ចូលរួមបណ្តាញ ធ្វើការតស៊ូមតិ ធ្វើជាតំណាងស្ត្រី និងក្រុមជនងាយរងគ្រោះ... និងចូលរួមគាំទ្រដោយស្ម័គ្រចិត្ត)*
- អនុវត្តបទពិសោធន៍លើកកម្ពស់ការចូលរួមរបស់យុវវ័យ និងក្រុមជនងាយរងគ្រោះរបស់គម្រោងអភិបាលកិច្ចសហគមន៍កុមារមេត្រី
- បង្កើនសមត្ថភាពក្រុមប្រឹក្សា ក្នុងការឆ្លើយតបឲបានប្រសើរ ចំពោះតម្រូវការរបស់ក្រុមជនងាយរងគ្រោះ
- កត់ត្រាទុកនូវយោបល់ត្រឡប់របស់ស្ត្រី និងក្រុមជនងាយរងគ្រោះ តាមរយៈកិច្ចប្រជុំបណ្តាញតាមមូលដ្ឋាន និងកិច្ចប្រជុំប្រចាំត្រីមាសជាមួយអ្នកពាក់ព័ន្ធ និងប្រើប្រាស់វាដើម្បីធ្វើការឆ្លុះបញ្ចាំងទៅនឹងយុទ្ធសាស្ត្រ និងការអនុវត្តន៍។

**សកម្មភាពក្រុមប្រឹក្សា ចុះដល់មូលដ្ឋាន និងកៀគរប្រពលរដ្ឋ ដើម្បីប្រមូលបញ្ហា និងធ្វើការដោះស្រាយជូនក្នុងករណីស្រាល និងបន្តរធ្វើការដោះស្រាយ ក្នុងករណីមានការសម្រេចច្រើន**

- ❖ ក្រុមប្រឹក្សាឃុំ សង្កាត់ ផ្លាស់ប្តូឥរិយាបទចំពោះស្ត្រី បុរស
- ❖ ក្រុមប្រឹក្សាបង្កើតគោលនយោបាយ ឬយុទ្ធសាស្ត្រ ឬ ផែនការសកម្មភាព លើកកម្ពស់យេនឌ័រ
- ❖ ក្រុមប្រឹក្សាអនុវត្តយុទ្ធសាស្ត្រ ឬសកម្មភាពលើកកម្ពស់យេនឌ័រ
- ❖ សហគមន៍មូលដ្ឋាន (CBO) ឬប្រជាពលរដ្ឋ ផ្លាស់ប្តូឥរិយាបទចំពោះការចូលរួម និងការទទួលបាន ឬទាមទារប្រយោជន៍ជូនស្ត្រី បុរស
- ❖ ក្រុមប្រឹក្សា ឬ សហគមន៍មូលដ្ឋាន (CBO) ឬយុវជន បង្កើតសកម្មភាព លើកកម្ពស់យេនឌ័រ ឬភាពអង់អាចដល់ស្ត្រី

ទោះជាយ៉ាងណា លទ្ធផលពីការស្រាវជ្រាវដែលរៀបចំដោយយុវជនវ័យក្មេងក្នុងក្រុងកំពង់ចាមបានបង្ហាញថា កំរិតនៃការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធអំពីអភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅមានកំរិតទាមនៅឡើយ។

អថេរដែលយុវជនបានលើកយកមកសិក្សា និងវាស់វែងពីការយល់ដឹងរបស់អាជ្ញាធរ អ្នកផ្តល់សេវាសាធារណៈ និងអ្នកពាក់ព័ន្ធផ្សេងៗមានដូចជា និយមន័យនៃអភិបាលកិច្ចល្អ គោលការណ៍នៃអភិបាលកិច្ចល្អ កត្តាដែលនាំឲ្យមានសង្គមល្អ តួនាទី និងការទទួលខុសត្រូវរបស់សង្កាត់ តួនាទី និងការទទួលខុសត្រូវរបស់ក្រុង ការកំណត់អត្តសញ្ញាណនៃការចូលរួម ការកំណត់អត្តសញ្ញាណពលរដ្ឋសកម្ម ការចូលរួមធ្វើផែនការអភិវឌ្ឍន៍នានា ការធ្វើផែនការអភិវឌ្ឍន៍សង្កាត់ ការធ្វើថវិកាអភិវឌ្ឍន៍សង្កាត់ ការធ្វើផែនការអភិវឌ្ឍន៍ក្រុង ការធ្វើថវិកាអភិវឌ្ឍន៍ក្រុង តម្លាភាពសេវាសាធារណៈ ការទទួលខុសត្រូវរបស់អ្នកសេវាសាធារណៈ សេវាការិយាល័យច្រកចេញចូលតែមួយ សេវាការិយាល័យប្រជាពលរដ្ឋ តួនាទី និងការទទួលខុសត្រូវរបស់គកនក/គកសក យន្តការច្រកចេញចូលតែមួយរបស់សង្កាត់ ការកំណត់អត្តសញ្ញាណបញ្ហាប្រឈមនៃសេវាសាធារណៈ សារៈសំខាន់នៃការប្រជុំពិគ្រោះយោបល់ ការរៀបចំការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាសង្កាត់ ការរៀបចំការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង សារៈសំខាន់នៃការតាមដានលើការធ្វើផែនការនិងថវិកា សារៈសំខន់នៃការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការលើកជាសំណូមពរ និងបញ្ហារបស់ប្រជាពលរដ្ឋ។

សរុបការយល់ដឹងជាមធ្យមភាគលើអថេរទាំងអស់ខាងលើ តាមតារាងលទ្ធផលខាងក្រោមបង្ហាញថា អ្នកដែលមិនយល់ដឹងសោះ មាន២២.៨% អ្នកយល់ដឹងតិចតួច មាន២៥% អ្នកយល់ដឹងបង្គួរ មាន៣៨.៨% អ្នកយល់ដឹងបានល្អ មាន១២.១% និងអ្នកដែលយល់ដឹងច្បាស់ មានចំនួន១.២%។

សំគាល់៖ អំពីការយល់ដឹង និងការផ្តល់សេវាសាធារណៈរបស់អាជញ្ញាធរក្រុងកំពង់ចាម និងអ្នកពាក់ព័ន្ធផ្សេងៗ អំពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ការកសាងផែនការថវិកាក្រុង និងការរៀបចំការប្រជុំសារធារណៈ ក្នុងនោះត្រូវបានរកឃើញមានគម្លាតដូចខាងក្រោម៖

- ការកសាងផែនការអភិវ្ឍន៍ក្រុង មិនមានអ្នកយល់ដឹងសោះចំនួន៤១% មានអ្នកយល់ដឹងតិចតួចចំនួន២៣.១% មានអ្នកយល់ដឹងបង្គួរចំនួន២៨.២% មានអ្នកយល់ដឹងបានល្អចំនួន៧.៧%។
- ការកសាងផែនការថវិកាក្រុង មិនមានអ្នកយល់ដឹងសោះចំនួន៥៣.៩% មានអ្នកយល់ដឹងតិចតួចចំនួន២០.៥% មានអ្នកយល់ដឹងបង្គួរចំនួន១៧% មានអ្នកយល់ដឹងបានល្អចំន័ន៧.៧%។
- ការរៀបចំការប្រជុំសាធារណៈរបស់សាលាក្រុងកំពង់ចាម មិនមានអ្នកយល់ដឹងសោះចំនួន៤0% មានអ្នកយល់ដឹងតិចតួច២២.៥% មានអ្នកយល់ដឹងបង្គួរចំនួន១៥% មានអ្នកយល់ដឹងបានល្អចំនួន១.៥% ។

**តារាងលទ្ធផលទី២៖** ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីអភិបាលកិច្ចមូលដ្ឋាន

| លរ | អថេរ | មិនយល់ដឹង | យល់ដឹងតិចតួច | យល់ដឹងជាបង្គួរ | យល់ដឹងបានល្អ | យល់ដឹងល្អណាស់ |
|---|---|---|---|---|---|---|
| 1 | និយមន័យនៃអភិបាលកិច្ចល្អ | 12.5% | 20.0% | 50.0% | 15.0% | 2.5% |
| 2 | គោលការណ៍នៃអភិបាលកិច្ចល្អ | 12.5% | 20.0% | 50.0% | 10.0% | 7.5% |
| 3 | កត្តាដែលនាំឲ្យមានសង្គមល្អ | 2.5% | 35.0% | 50.0% | 12.5% | 0.0% |
| 4 | តួនាទី និងការទទួលខុសត្រូវរបស់សង្កាត់ | 10.0% | 15.0% | 55.0% | 20.0% | 0.0% |
| 5 | តួនាទី និងការទទួលខុសត្រូវរបស់ក្រុង | 30.0% | 27.5% | 35.0% | 7.5% | 0.0% |
| 6 | ការកំណត់អត្តសញ្ញាណនៃការចូលរួម | 7.5% | 37.5% | 45.0% | 10.0% | 0.0% |
| 7 | ការកំណត់អត្តសញ្ញាណពលរដ្ឋសកម្ម | 7.5% | 30.0% | 47.5% | 12.5% | 2.5% |
| 8 | ការចូលរួមធ្វើផែនការអភិវឌ្ឍន៍នានា | 35.0% | 17.5% | 40.0% | 7.5% | 0.0% |
| 9 | ការធ្វើផែនការអភិវឌ្ឍន៍សង្កាត់ | 12.5% | 22.5% | 50.0% | 12.5% | 2.5% |
| 10 | ការធ្វើថវិកាអភិវឌ្ឍន៍សង្កាត់ | 25.0% | 27.5% | 37.5% | 10.0% | 0.0% |
| 11 | ការធ្វើផែនការអភិវឌ្ឍន៍ក្រុង | 41.0% | 23.1% | 28.2% | 7.7% | 0.0% |
| 12 | ការធ្វើថវិកាអភិវឌ្ឍន៍ក្រុង | 53.9% | 20.5% | 17.9% | 7.7% | 0.0% |
| 13 | តម្លាភាពសេវាសាធារណៈ | 15.0% | 35.0% | 37.5% | 12.5% | 0.0% |
| 14 | ការទទួលខុសត្រូវរបស់អ្នកសេវាសាធារណៈ | 25.0% | 32.5% | 30.0% | 12.5% | 0.0% |
| 14 | សេវាការិយាល័យច្រកចេញចូលតែមួយ | 20.0% | 30.0% | 32.5% | 17.5% | 0.0% |
| 15 | សេវាការិយាល័យប្រជាពលរដ្ឋ | 20.0% | 22.5% | 45.0% | 12.5% | 0.0% |
| 16 | តួនាទី និងការទទួលខុសត្រូវរបស់គកនក/គកសក | 42.5% | 15.0% | 32.5% | 10.0% | 0.0% |
| 17 | យន្តការច្រកចេញចូលតែមួយរបស់សង្កាត់ | 20.0% | 22.5% | 40.0% | 15.0% | 2.5% |
| 18 | ការកំណត់អត្តសញ្ញាណបញ្ហាប្រឈមនៃសេវាសាធារណៈ | 33.3% | 12.8% | 38.5% | 15.4% | 0.0% |
| 19 | សារៈសំខាន់នៃការប្រជុំពិគ្រោះយោបល់ | 20.0% | 25.0% | 37.5% | 15.0% | 2.5% |
| 20 | ការរៀបចំការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាសង្កាត់ | 15.0% | 27.5% | 37.5% | 15.0% | 5.0% |
| 21 | ការរៀបចំការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង | 40.0% | 22.5% | 20.0% | 15.0% | 2.5% |
| 22 | សារៈសំខាន់នៃការតាមដានលើការធ្វើផែនការនិងថវិកា | 25.0% | 27.5% | 37.5% | 10.0% | 0.0% |
| 23 | សារៈសំខន់នៃការចូលរួមធ្វើសេចក្តីសម្រេចចិត្ត | 25.0% | 30.0% | 35.0% | 10.0% | 0.0% |
| 24 | ការលើកជាសំណូមពរ និងបញ្ហារបស់ប្រជាពលរដ្ឋ | 20.5% | 25.6% | 41.0% | 10.3% | 2.6% |
| | **ជាមធ្យមភាគ** | **22.8%** | **25.0%** | **38.8%** | **12.1%** | **1.2%** |

## ៦.សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលស្រាវជ្រាវនេះ វាបានបង្ហាញឲ្យឃើញថា ទាំងយុវជន ប្រជាសហគមន៍ មន្ត្រីរាជការ និងអ្នក អ្នកពាក់ព័ន្ធសំខាន់ៗ នៅក្នុងសង្កាត់ទាំង៤ នៃក្រុងកំពង់ចាម នៅមានកំរិតទាមនៅឡើយស្តីពីការយល់ដឹង និង អាចបកស្រាយបានអំពីនិយមន័យនៃអភិបាលកិច្ចមូលដ្ឋាន និងសេវាកម្មសាធារណៈ ។

**ការរកឃើញទី១៖** អ្នកមិនយល់ដឹងសោះអំពីអភិបាលកិច្ចមូលដ្ឋាន និងសេវាកម្មសាធារណៈ មាន៧២% អ្នកយល់ដឹងតិចតួច មាន១៧.៧% អ្នកយល់ដឹងជាបង្គួរ មាន៧.៤% អ្នកយល់ដឹងល្អ មាន២.៥% និង យល់ដឹងច្បាស់ មានចំនួន0.៤% ។

**អនុសាសន៍១.១៖** ដើម្បីឆ្លើយតបទៅនឹងការរកឃើញខាងលើ ប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាក្រុងកំពង់ចាមគួរសម្របសម្រួលឱកាសឲ្យយុវជន ប្រជាពលរដ្ឋសហគន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជាសង្គមស៊ីវិលបានចូលរួមប្រជុំជាមួយសង្កាត់ និងក្រុងជាប្រចាំ និងទៀងទាត់ (ប្រជុំប្រចាំខែ ប្រជុំពិគ្រោះយោបល់ និងវេទិកា/ព្រិត្តិការណ៍ផ្សេងៗដើម្បីអនុញ្ញាតឲ្យយុវជន ប្រជាពលរដ្ឋសហគន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតបានទទួលព័ត៌មាន និង

ចំណេះដឹងអំពីអភិបាលកិច្ចមូលដ្ឋាន គោលការណ៍អភិបាលកិច្ចល្អ ជាពិសេសគឺដើម្បីទទួលសាវាកម្មសង្កាត់ និងក្រុងប្រកបដោយតម្លាភាព គណនេយ្យភាព សុចរឹតភាព សមភាព ប្រសិទ្ធភាព និងយុត្តិធម៌។ បន្ថែមជាមួយការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋអំពីនីតិវិធីនៃការផ្តល់សេវាសាធារណៈ និងតម្រូវការឯកសារពាក់ព័ន្ធត្រូវយកទៅជាមួយនៅពេលធ្វើឯកសារអ្វីមួយ។

**អនុសាសន៍១.២៖** ប្រឹក្សាសង្កាត់ និងក្រុងគួររៀបចំ និងផ្សព្វផ្សាយកាលវិភាគនៃការប្រជុំប្រចាំខែរបស់ខ្លួនដល់យុវជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធឲ្យបានទូលំទូលាយ លើសពីការបិទលើក្តាព័ត៌មាន ដើម្បីបង្កឱកាសឲ្យពួកគេបានចូលរួមប្រជុំផងដែរក្នុងគោលបំណងឆ្លើយតបទៅនឹងគោលការណ៍អភិបាលកិច្ចល្អ ស្របតាមបច្ចេកទេសណែនាំរបស់គណកម្មាធិការជាតិដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យ។ យោងអនុក្រិតលេខ២២អនក្របក ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០២ ស្តីពីការវិមជ្ឈការ តួនាទី និងភារកិច្ចរបស់ឃុំសង្កាត់ នៅមាត្រា ៣០ ដល់ ៣៣ ប្រជាពលរដ្ឋមានសិទ្ធិពេញលេញចូលរួមក្នុងកិច្ចការសាធារណៈរបស់ឃុំសង្កាត់ ។

**ការរកឃើញទី២៖** ការយល់ដឹងរបស់ប្រជពលរដ្ឋអំពីតួនាទី និងការផ្តល់សេវារបស់រដ្ឋបាលសង្កាត់ និងក្រុង ជាលទ្ធផលមធ្យមភាគ វាបង្ហាញឲ្យឃើញថា មានអ្នកមិនយល់សោះ មាន៧៥% អ្នកយល់តិចតួច មាន១៥.៩% អ្នកយល់ដឹងបង្គួរ មាន៦.៧% អ្នកយល់ដឹងបានល្អ មាន១.៩% និងអ្នកយល់ដឹងល្អណាស់ មាន០.៥%។

**អនុសាសន៍២.១៖** ប្រឹក្សាសង្កាត់ និងក្រុងគួរបង្កឱកាសឲ្យយុវជន ប្រជាសហគមន៍ និងសង្គមស៊ីវិលបានចូលរួមក្នុងការងាររបស់គណៈកម្មាធិការនានារបស់សង្កាត់ និងក្រុង ដូចជាគណៈកម្មាធិការកសាងផែនការ និងថវិការបស់សង្កាត់ និងក្រុងដើម្បីបានចូលរួមលើកជាបញ្ហា ការសម្រេចចិត្ត និងតាមដានរាល់សកម្មភាព និងរាល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាសង្កាត់ និងក្រុងផងដែរ។

**អនុសាសន៍២.២៖** ក្រុងប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាក្រុង និងអ្នកបំរើសេវាសាធារណៈគួរចូលធ្វើការម៉ោង៧:០០ព្រឹកតាមម៉ោងពេល ការផ្តល់សេវាឲ្យបានលឿន សមរម្យ ថ្លៃថ្នូរ និងត្រឹមត្រូវ ជៀសវាងមានកំហុសលើឯកសារដូចជាអត្តសញ្ញាណប័ន សំបុត្រកំណើត និងសៀវភៅគ្រួសារជាដើម។ លើសពីនេះ មន្ត្រីបំរើការងារនៅសង្កាត់ និងក្រុងស្នើឲ្យមានភាពសមរម្យ កុំតឹងតែង នៅពេលប្រជាពលរដ្ឋទៅរកសេវា។

**អនុសាសន៍២.៣៖** ក្រុមប្រឹក្សាសង្កាត់ និងក្រុងគួរចុះផ្ទាល់មកមើលប្រជាពលរដ្ឋតាមភូមិ ថាតើពួកគាត់ពិតជាក្រីក្រ ពិតជាត្រូវការជំនួយមែនទេ មុនពេលផ្តល់ប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋ។ ភូមិឃុំ និងក្រុងគួរដើរមើលប្រជាពលរដ្ឋដើម្បីដោះស្រាយទំនាស់ និងតម្រូវការភាពខ្វះខាតរបស់យុវជន និងប្រជាពលរដ្ឋដោយមានតម្លាភាព គណនេយ្យភាព សុចរិតភាព និងស្មើភាព។

**អនុសាសន៍២.៤៖** ប៉ូលីស ក្រុមប្រឹក្សាសង្កាត់ និងក្រុងសូមជួយមើលបញ្ហាក្មេងទំនើង ការបង្ហោះម៉ូតូ គ្រឿងញៀន អំពើហឹង្សា និងអសន្តិសុខនានាដែលកើតមាននៅភូមិឃុំ ដើម្បីរក្សាបាននូវភូមិឃុំសុវត្ថិភាព អនាម័យបរិស្ថាន និង

ការអភិវឌ្ឍជឿនលឿន ។ ជាមួយគ្នានោះដែរ ក្រុមប្រឹក្សាសង្កាត់ និងក្រុងគួរពិចារណាធ្វើផ្លូវថ្នល់ ភ្លើង លូ ឲ្យបានលឿនៗ និងអភិវឌ្ឍន៍ក្រុងប្រកបដោយបៃតង។

**ការរកឃើញទី៣៖** ការដឹង និងស្គាល់របស់ប្រជាពលរដ្ឋសហគមន៍អំពីការិយាល័យច្រក និងសេវាសាធារណៈ នៅកំរិតសង្កាត់ និងក្រុងកំពង់ចាម គិតជាមធ្យមភាគ អ្នកមិនស្គាល់ ឬមិនដឹង មានចំនួន៦១.៩% និងអ្នកដឹង ឬស្គាល់មានចំនួន៣៨.៩១% ។

**អនុសាសន៍៣.១៖** ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មរបស់ខ្លួន និងដើម្បីបង្កើនការយល់ដឹងដល់មនុស្សវ័យក្មេង និងប្រជាពលរដ្ឋ គ្រប់ការិយាល័យបម្រើសេវាសាធារណៈ ជាពិសេសការិយល័យសេវាច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ ការិយាល័យសង្គមកិច្ច ករិយាល័យទទួលបន្ទុកកិច្ចការនារី និងកុមារត្រូវផ្សព្វផ្សាយសេវាកម្មរបស់ខ្លួនឲ្យបានទូលំទូលាយ បង្កើនការចុះសួរសុខទុក និងពិនិត្យតាមដាន និងរៀបចំវេទិការពិគ្រោះយោបល់ជាមួយអ្នកទទួលផល ប្រជាសហគមន៍ និងអ្នកពាក់ព័ន្ធនានាឲ្យបានយ៉ាងតិច៤ដងក្នុងមួយឆ្នាំ ដោយមានកិច្ចសហការណ៍ល្អជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។

**ការរកឃើញទី៤៖** ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធអំពីអភិបាលកិច្ចមូលដ្ឋាន និងសេវាកម្មសាធារណៈ វាបានបង្ហាញថា អ្នកដែលមិនយល់ដឹងសោះ មាន២២.៨% អ្នកយល់ដឹងតិចតួច មាន២៥% អ្នកយល់ដឹងបង្គួរ មាន៣៨.៨% អ្នកយល់ដឹងបានល្អ មាន១២.១% និងអ្នកដែលយល់ដឹងច្បាស់ មានចំនួន១.២% ជាមធម្យភាគ។

**អនុសាសន៍ទី៤.១៖** ទាំងអាជ្ញាធរនៅកំរិតសង្កាត់ ក្រុង និងការិយាល័យពាក់ព័ន្ធមានចំណេះដឹងជាបង្គួរស្តីពីអភិបាលកិច្ចមូលដ្ឋាន និងសេវាសាធារណៈក៏ដោយ ពួកគេនៅត្រូវការការបណ្តុះបណ្តាល និងការតំរង់ទិសបន្ថែម ការិយាល័យ មន្ទីរ ឬក្រសួងជំនាញដើម្បីគាទ្របច្ចេកទេស និងពង្រឹងគុណភាពនៃការអនុវត្តតួនាទី ភារកិច្ច និងសេវាកម្មរបស់ឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ដូចនេះ ការិយាល័យជំនាញនៅកំរិតខេត្ត និងក្រសួងត្រូវបន្តការបណ្តុះបណ្តាល ការចុះត្រួតពិនិត្យ និងវាយតម្លៃលើគុណភាពនៃការផ្តល់សេវារបស់សង្កាត់ និងក្រុងឲ្យបានទៀតទាត់ ស្របតាមការណែនាំបច្ចេកទេសរបស់គណកម្មាធិការជាតិដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។

**ការរកឃើញទី៥៖** ការយល់ដឹង និងការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាក្រុងកំពង់ចាម អំពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ការកសាងផែនការថវិកាក្រុង និងការរៀបចំការប្រជុំសារធារណៈ ក្នុងនោះត្រូវបានរកឃើញមានគម្លាតដូចខាងក្រោម៖

❖ ការកសាងផែនការអភិវ្ឍន៍ក្រុង មិនមានអ្នកយល់ដឹងសោះចំនួន៤១% មានអ្នកយល់ដឹងតិចតួចចំនួន២៣.១% មានអ្នកយល់ដឹងបង្គួរចំនួន២៨.២% មានអ្នកយល់ដឹងបានល្អចំនួន៧.៧%។

- ការកសាងផែនការថវិកាក្រុង មិនមានអ្នកយល់ដឹងសោះចំនួន៥៣.៩% មានអ្នកយល់ដឹងតិចតួចចំនួន ២០.៥% មានអ្នកយល់ដឹងបង្គួរចំនួន១៧% មានអ្នកយល់ដឹងបានល្អចំន័ន៧.៧%។
- ការរៀបចំការប្រជុំសាធារណៈរបស់ក្រុងកំពង់ចាម មិនមានអ្នកយល់ដឹងសោះចំនួន៤០% មានអ្នកយល់ដឹងតិចតួច ចំនួន២២.៥% មានអ្នកយល់ដឹងបង្គួរចំនួន១៥% មានអ្នកយល់ដឹងបានល្អចំនួន១.៥%។

**អនុសាសន៍ទី៥.១៖** ក្រុមប្រឹក្សាសង្កាត់ និងក្រុងគួរជំរុញ និងលើកទឹកចិត្តឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងដំណើរការកសាងផែនការ និងការរៀបចំថវិកា ដើម្បីជំរុញឱ្យមានអារម្មណ៍នៃភាពជាម្ចាស់ ការជឿទុកចិត្ត តម្លាភាព គណនេយ្យភាព និងគុណភាពនៃសេវាកម្មរបស់ខ្លួន។ ពីព្រោះថា នៅពេលដែលភាគីពាក់ព័ន្ធចូលរួមក្នុងការសម្រេចចិត្ត និងមានតម្លាភាពទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ ពួកគេទំនងជាគាំទ្រគម្រោង និងរួមចំណែកដល់ភាពជោគជ័យរបស់វា។

មានសំណួរមួយបានសួរថា ហេតុអ្វីយើងត្រូវការសេវាសាធារណៈល្អ? សេវាសាធារណៈល្អគឺសំខាន់ណាស់សម្រាប់អ្នកចូលទៅប្រើប្រាស់សេវាសាធារណៈ ជាពិសេសប្រជាពលរដ្ឋ និងក្រុមជនងាយរងគ្រោះផ្សេងៗ។ វាមានហេតុផលជាច្រើនជាឧត្តមគតិ ហើយវាអាស្រ័យលើសេវាសាធារណៈជាក់លាក់ណាមួយដែលកំពុងត្រូវបានពិចារណា។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ អ្នកជំនាញអាចសម្រេចចិត្តបន្តអាជីពក្នុងសេវាសាធារណៈពីព្រោះថាវាអាចជួយសង្គ្រោះជីវិតមនុស្ស បង្កើនគុណភាពជីវិត ធ្វើការឆ្ពោះទៅរកការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងផ្តល់ឱកាសឱ្យមនុស្សជំនាន់ក្រោយកាន់តែប្រសើរឡើង តាមរយៈខ្នាតគំរូនៃការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាសង្កាត់ និងក្រុងកំពង់ចាមនាពេលបច្ចុប្បន្ន។

ដើម្បីគុណភាព និងប្រសិទ្ធភាពនៃដំណើរការអភិវឌ្ឍ រាជរដ្ឋាភិបាលបានចេញអនុក្រិត្យស្តីពីផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដើម្បីលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងការចូលរួបពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ មាត្រា៥នៃអនុក្រិត្យនេះបានចែងថា ការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រព្រិត្តទៅតាមគោលការណ៍រួម គឺការចែករំលែក តម្លាភាព សង្គតិភាពនិងសុខដុមនីយកម្ម ការចូលរួមពិគ្រោះយោបល់ ការឆ្លើយតបនឹងតម្រូវការ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រសិទ្ធភាពនិងសុចរឹតភាពសេដ្ឋកិច្ចនិងសង្គម ការធានាចីរភាពធនធានធម្មជាតិនិងបរិស្ថាន និងការធានាសមធម៌។

**៧.ឯកសារយោង៖**

១.សៀវភៅស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុងតាមបែបវិមជ្ឈការ (សម្រាប់ក្រុមប្រឹក្សាក្រុង) របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ឆ្នាំ២០១៩។

២.សៀវភៅស្តីពីអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ

៣.ឯកសារបណ្តុះបណ្តាល ស្តីពីគោលនយោបាយនៃការផ្តល់សេវាសាធារណៈ និងទស្សនទាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយរបស់នាយកដ្ឋានមុខាង និងធនធាន អគ្គនយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

៤.អនុក្រិត្យស្តីពីផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៥.អនុក្រិត្យស្តីពីការផ្ទេរវិមជ្ឈការ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

៦.ឯកសារបច្ចេកទេសស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

៧.វេបសាយ https://angkorsetha.wordpress.com

៨.វេបសាយ https://www.rfi.fr/km/cambodia/sub-national-governance-rfi-oudom-06-02-2017

៩.វេបសាយ https://km.wikipedia.org/wiki/ការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ